- បញ្ជារបស់បិតាខ្ញុំ ទោះយ៉ាងណាក៏ខ្ញុំត្រូវតែអនុវត្ត ។ អស់លោកសម្រេចភារកិច្ចរបស់ខ្លួនចុះ, ខ្ញុំអត់ប្រកែកប្រណាំងអ្វីទេ ។ ប៉ុន្តែ ទោះយ៉ាងណាក៏ខ្ញុំនៅតែគិតថាខ្ញុំគ្មានកំហុស, ទាំងជាមួយរាជបល្ល័ង្កក៏ដូចប្រទេសជាតិ ។

កងសេះយកច្រវាក់ធំទាក់អាឡាដាំង ហើយរុំផ្ដោបដៃទាំងពីរចូលដងខ្លួនអត់ឱ្យកម្រើកបាន ។ បន្ទាប់នោះលោកមេទ័ពជិះសេះនាំមុខក្បួន ។ ទាហានម្នាក់ជិះសេះអម ដោយកាន់ចុងច្រវាក់ដឹកអាឡា-ដាំងដើរតាម ។ ចំណែកទាហានឯទៀតនៅការពារពីក្រោយ ។ គេចាប់បញ្ជូននាយតាមរបៀបនេះតាំងពីក្រៅក្រុងរហូតចូលដល់ក្នុងក្រុង ។

គ្រាន់តែកងសេះឆ្លងផុតខ្លោងទ្វារកំពែងក្រុងភ្លាម មនុស្សម្នាផ្អើលគិល ។ ដោយហេតុអ្នកផងធ្លាប់មានសមានចិត្តចំពោះអាឡាដាំងពេលនោះឃើញនាយស្រាប់តែត្រូវជាប់ចំណងដូចអ្នកទោសឧក្រិដ្ឋ ក៏ស្រែកអឺងកងតវ៉ា ខ្លះទាញដាវ ខ្លះទាញពូថៅរត់តាមវាយរំដោះ ។ ដំបូងក្រុមទាហានការពារក្បួន ដោយអាងអំណាចវាំង ប្រុងបំបែកហ្វូងពួកប៉ះបោរដោយប្រើកម្លាំងបាយ ។ តែអ្នកស្រុកសម្រុកចូលលែងញញើតតួនាទីដូចមុន ក៏រកមធ្យោបាយទប់ទល់វិញ ដើម្បីលៃយ៉ាងណាទៅឱ្យដល់វាំង ។ គេបំបែកគ្នាជាពីរជួរ ការពារសងខាង, ខ្សែការពារជូនរូមចូលជូនរីកធំអាស្រ័យលើទំហំផ្លូវ ទប់មិនឱ្យអ្នកស្រុកចូលកៀកដណ្ដើមអាឡាដាំងបាន ។ ដោយអនុវត្តរបៀបនេះ គេអាចរំកិលបន្តិចម្ដងៗរហូតទាល់តែចូលដល់វាំង ហើយនាំគ្នាបិទទ្វារកំពែងដាក់គន្លឹះជាប់ ។



ព្រះរាជាកំពុងគង់លើយ៉ប្រាសាទជាមួយលោកឧបរាជ, ឃើញគេនាំអាឡាដាំងចូលមកក៏បញ្ជាពេជ្ឈឃាតចាប់ផ្ដើមស្រាយចំណងច្រវាក់ទាក់កអាឡាដាំង បន្ទាប់មកក្រាលស្បែកសត្វមួយផ្ទាំង ដែលប្រឡាក់សុទ្ធតែឈាមអ្នកទោស, ក្រាលរួចបង្គាប់នាយឱ្យលុតជង្គង់ឡើង ហើយយកក្រណាត់ចងភ្នែកទាំងសងខាង ។ ចប់កិច្ចការនេះ គេហូតដាវគ្រវីបីជុំប៉ប្រះក្បាលអាឡាដាំង ជាសញ្ញារង់ចាំបញ្ជាចុងក្រោយ អាលកាត់ផ្ដាច់ក្បាលពីដងខ្លួន ដូចដែលគេធ្លាប់អនុវត្តហូរហែតាំងពីដើមមក ។

ប៉ុន្តែទន្ទឹមនឹងពេជ្ឈឃាតគ្រវីដាវវីបៗ លោកឧបរាជស្រាប់តែក្រឡេកទៅឃើញក្រុមមនុស្សប៉ះបោរឡើងតាមកំពែងវាំងទាំងហ្វូងៗ ខ្លះសម្រុកចូលតាមទ្វារវាំង ហើយវាយសម្រុកកងអង្គរក្សជួរទីមួយ, រីឯនៅជ្រុងម្ខាងទៀត កំពែងវាំងត្រូវបាក់រលំ មានមនុស្សម្នាកាន់អាវុធគ្រប់ដៃរត់ចូលដូចទឹកបាក់ទំនប់ ។ តាមមើលពួកអង្គរក្សពុំអាចការពារទប់ទល់នឹងហ្វូងមនុស្សបានឡើយ ។ ស្រាប់តែគាត់ស្រែកភ្លាត់សម្លេង :

- មិនស្រួលទេព្រះអង្គ, ប្រជានុរាស្ត្រលែងកោតក្រែងព្រះជេស្ដាហើយ មុខតែកំទេចគ្មានសល់អ្វីទាំងអស់ ប្រសិនបើមិនផ្អាកការប្រហារជីវិតអាឡាដាំងនៅពេលនេះ ។

ពួដូច្នេះ ព្រះរាជាងាកមើលតាម ស្រាប់តែទ្រង់ភ័យជាងលោកឧបរាជទៅទៀត ។ មិនបង្អង់យូរ ព្រះអង្គបញ្ជាឱ្យពួកពេជ្ឈឃាតស៊កដាវចូលស្រោមវិញ និងស្រាយមុខអាឡាដាំងជាប្រញាប់, ជាមួយគ្នានោះទ្រង់ប្រកាសលើកលែងទោសនាយ ព្រមទាំងប្រាប់គេឱ្យដំណឹងទៅអ្នកបះបោរពីការសម្រេចហឫទ័យនេះដើម្បីឱ្យគេបញ្ឈប់ការវាយសម្រុក ។

ពួកអ្នកបះបោរមួយចំនួនដែលនៅលើកំពែងវាំង មិនទាន់ចុះដល់ដី មើលមកឃើញគេបកមុខអាឡាដាំងវិញក៏ស្រែកបន្តប្រាប់គ្នីគ្នារួចនាំគ្នាថយទៅវិញ ដោយនាំទៅជាមួយនូវក្ដីរីករាយក្នុងជ័យជម្នះរំដោះអាឡាដាំង។ មិនយូរប៉ុន្មានទីលានប្រយុទ្ធក្នុងបរមរាជវាំងវិលទៅរកភាពស្ងប់ស្ងាត់ដូចដើម ។

បន្ទាប់ពីបានរួចខ្លួន អាឡាដាំងងើយរកមើលព្រះរាជា លុះឃើញព្រះអង្គកំពុងគង់លើយ៉ប្រាសាទក៏បន្លឺសួរ :

- ក្រាបទូលព្រះបិតា, សូមព្រះបិតាអនុញ្ញាតឱ្យបានដឹងផងតើទូលបង្គំមានទោសកំហុសអ្វី បានជាត្រូវទទួលការវិនិច្ឆ័យដូចពួកពានវាំងយ៉ាងនេះ, ក្រាបទូល?

- អូ, អាចង្រៃឯងអត់ទាន់ដឹងទោសកំហុសរបស់ខ្លួនមែនឬ? (ព្រះរាជាតប) ឡើងមកណេះ, យើងបង្ហាញឱ្យមើល ។

ពេលអាឡាដាំងឡើងតាមជណ្ដើរទៅដល់ខាងលើ ព្រះរាជាសម្លក់ដាក់នាយ :



ដើរតាមយើងភ្លាមមក៏ !

ថាហើយព្រះអង្គយាងរឹង១ក្នុងអាការៈក្រោធពិរោធហួសប្រមាណ, លុះទៅដល់បន្ទប់ទំនេរ ទ្រង់បែរមកសម្លក់ទៀត :

- ចូលទៅ, ហើយប្រាប់យើងឱ្យដឹងផងមើល តើវិមានរបស់ឯងនៅឯណា?

អាឡាដាំងចូលក្នុងបន្ទប់ ឈរសម្លឹងតាមបង្អួចស្រាប់តែភ្ញាក់ស្រាលខ្លួនដូចសំឡី, វិមានដ៏ស្កឹមស្កៃបំផុតនោះបាត់ស្រមោលឈឹងសូន្យ សល់តែវាលទំនេរស្អាត, ក្រៅពីទីវាលល្ហល្ហេវគ្មានស្លាកស្នាមអ្វីឡើយ ។ បាតុភូតនេះចម្លែកពន់ពេកធ្វើឱ្យនាយស្រឡាំងកាំងផង តក់ស្លុតផងដល់ថ្នាក់ហាមាត់និយាយលែងរួច ។

ឃើញដូច្នេះព្រះរាជាគំហក :

- និយាយឱ្យឆាប់, វិមានរបស់ឯងនិងបុត្រីយើងកំពុងនៅកន្លែងណា?

អាឡាដាំងខំប្រមូលសេចក្ដីក្លាហាន បន្លឺឡើង :

- ក្រាបទូលព្រះបិតា, ទូលបង្គំសូមសារភាពត្រង់ថា ទូលបង្គំមើលមិនឃើញវិមានរបស់ខ្លួននៅត្រង់កន្លែងចាស់ទេ, ពុំដឹងវាទៅណាបាត់ហើយ ហើយទូលបង្គំក៏មិនអាចទូលថ្វាយជាក់លាក់ថាវាកំពុងឋិតនៅត្រង់ណាដែរ ។ ឧប្បត្តិហេតុនេះចម្លែកពន់ពេក, ទូលបង្គំអត់មានពាក់ព័ន្ធទាល់តែសោះក្រាបទូល ។

- វិមានរបស់ឯងយ៉ាងណាស្រេចតែឯងចុះ យើងមិនត្រូវការដឹងទេ, (ព្រះរាជាបន្លឺសម្លេង) ប៉ុន្តែបុត្រីយើងមានតម្លៃលើសវិមានរាប់លានដងទៅទៀតនោះ ឯងត្រូវរកមកវិញឱ្យឆាប់ បើរកមិនឃើញដាច់ខាតកាត់ក្បាលឯងចោល, ម្តងណេះគ្មាននរណាឃាត់យើងបានទេ

- ក្រាបទូលបិតា, (អាឡាដាំងបន្ទន់ខ្លួននិយាយញ័រៗ) សូមព្រះបិតាប្រទានពេលវេលាសែសិបថ្ងៃ ដើម្បីទូលព្រះបង្គំតាមយកមកវិញ ទាំងវិមានទាំងរាជធីតា ។ ផុតរយៈពេលនោះបើអត់ទទួលបានលទ្ធផលអ្វី ទូលបង្គំនឹងយកក្បាលមកតម្កល់ប្របរាជបល្លង្ក ថ្វាយព្រះបិតាវិនិច្ឆ័យទោស, ក្រាបទូល ។

ព្រះរាជាងក់ព្រះកេសបន្ទាប់ពិសញ្ជឹងបន្តិច :

បាន ! យើងទុកពេលឱ្យសែសិបថ្ងៃតាមសំណូមពរ, ប៉ុន្តែឯងកុំសង្ឃឹមកេងប្រវ័ញ្ចមនោសញ្ចេតនានេះរត់គេចខ្លួនបាន ។ ទោះឯងឡើងសម្ងំពួនលើមេឃក៏យើងមានមធ្យោបាយអូសចុះវិញកាត់ក្បាលដែរ ។

អាឡាដាំងដើរចេញទាំងក្រៀមក្រំស្រពាប់ស្រពោន, ដំណើរទុរន់ទុរាគួរសង្វេគ ។ នាយឈ្ងោកមុខអត់មើលនរណាទាំងអស់ ។ ពួកមន្ត្រីវាំងធ្លាប់រាប់អាននាយ ពេលនេះអត់ហ៊ានមកជិតនិយាយលួងលោមលើកទឹកចិត្ត ឬហៅទៅស្នាក់នៅផ្ទះឡើយ, ម្នាក់ៗខ្លាចមានរឿងដល់ខ្លួនគិតតែឈរស្ងៀមដកដង្ហើមវែង ហើយងាកមុខចេញ ។



ប៉ុន្តែបើទុកជាមានអ្នកណាមកនិយាយលួងលោម ឬសន្យាជួយរួមដៃដោយប្រការណាមួយ គេមុខតែភ្ញាក់មិនខាន ព្រោះអាឡាដាំងបាត់ភាពរហ័សរហួនរួសរាយអស់រលីង កំពុងក្លាយជាមនុស្សម្នាក់វិលវល់យ៉ាងចម្លែក ។ ប្រការនេះអាចសម្គាល់ឃើញច្បាស់ពេលនាយចេញផុតពីវាំង ។ នាយដើរសួរពីផ្ទះមួយទៅផ្ទះមួយនិងសួរគ្រប់អ្នកដំណើរតាមផ្លូវតើដឹងវិមានរបស់ខ្លួននៅឯណាទេ, បើដឹងសូមមេត្តាប្រាប់ផង ។

គ្មាននរណាម្នាក់ដែលមិនដឹងថាអាឡាដាំងឈានដល់ដំណាក់កាលឡប់ស្មារតីឡើយ ។ ប៉ុន្តែគេបានត្រឹមតែអាណិតប៉ុណ្ណោះ ពុំដឹងជួយយ៉ាងម៉េចកើត ។

អាឡាដាំងវិលវល់បីថ្ងៃបីយប់ក្នុងរាជធានី, ម្តងទៅជើងម្តងទៅត្បូង ដើររកវិមានរបស់ខ្លួន, អ្នកណាឱ្យអ្វីទទួលទានហ្នឹង បើមិនឱ្យទេ គិតតែដើរចច្រប់លែងដឹងឃ្លានដឹងស្រេក ។ ទីបំផុតនាយមិនអាចទ្រាំស្ថានភាពបែបនេះតទៅទៀតបាន ក៏ចេញទៅជនបទវិញហើយជ្រើសយកផ្លូវក្នុងព្រៃសម្រាប់ធ្វើដំណើរដើម្បីកុំឱ្យគេឃើញមុខ ។ ល្ងាចថ្ងៃទីបួន ពេលព្រះអាទិត្យហៀបអស្តង្គត នាយមកដល់ទន្លេមួយធំគួរសម ។ នៅទីនោះ បន្ទាប់ពីឈរសំរាកបន្តិច នាយចាប់ផ្តើមអស់សង្ឃឹមនឹកក្នុងចិត្ត: "យើងតាមរកវិមាននៅឯណា, ខេត្តណា, ប្រទេសណា, កន្លែងណាលើផែនដី? អាចរកឃើញទេ? បើគង់តែគ្មានសង្ឃឹម

ដដែល យកល្អ បញ្ចប់ការលំបាកវេទនានេះក្នុងពេលឥឡូវនេះទៅ" ។

សម្រេចចិត្តរួច អាឡាដាំងប្រុងលោតទឹកសម្លាប់ខ្លួនជាដាង ត្រូវគេកាត់ក្បាលដូចសត្វធាតុ ប៉ុន្តែដោយហេតុជាអ្នកមានជំនឿស៊ប់លើសាសនា នាយនឹកឃើញថាមិនត្រូវធ្វើការងារនេះដោយអត់ទាន់បានសូត្រធម៌ថ្វាយបង្គំព្រះឡើយ ។ ភ្លាមនោះនាយចុះមាត់ទឹក ដើម្បីលប់មុខនិងលាងដៃជើងអាលឡើងមកវិញថ្វាយបង្គំព្រះ ។ ប៉ុន្តែមាត់ច្រាំងចោតផងរអិលផង នាយទើបតែចុះទើម១ ក៏រអិលដួលទាំងជំហរវិះ បន្តិចទៀតដាំដូងចុះទឹកប្រសិនបើមិនរហ័សដៃស្រវាចាប់ចុងថ្មដែលលូតផុតពីទឹកប្រហែលពីរហត្ថ ។ សំណាងល្អ ពេលនាយចាប់ផ្ទាំងថ្ម ទប់ខ្លួននោះ ចិញ្ចៀនទិព្វនៅម្រាមដៃនាយត្រូវកកិតចូលថ្មយ៉ាងខ្លាំង បន្ទាន់នឹងកម្លាំងកកិតស្រាប់តែលេចចម្លែកដែលធ្លាប់ជួយសង្គ្រោះនាយម្តងក្នុងរូងក្រោមដី បង្ហាញខ្លួនថ្ងោង បន្លឺសួរយ៉ាងគោរព :

- ចៅហ្វាយម្ចាស់ត្រូវការអីដែរ? រូបខ្ញុំនិងទាសករទាំងអស់របស់ចិញ្ចៀននេះ ត្រៀមខ្លួនជានិច្ចចាំទទួលបញ្ជាពីចៅហ្វាយម្ចាស់ ឬអ្នកណាក៏ដោយដែលពាក់ចិញ្ចៀននេះក្នុងដៃ ។

ការមកដល់ដោយចៃដន្យរបស់ទេពចម្លែកធ្វើឱ្យអាឡាដាំងហាក់មានសង្ឃឹមឡើងវិញ នាយញញឹមតប :

- អ្នកឯងធ្លាប់ជួយយើងម្តងកាលយើងរងគ្រោះលើកមុន ។



ពេលនេះយើងកំពុងមានទុក្ខធំណាស់ អ្នកឯងប្រាប់មកមើល៍ វិមានរបស់យើងកំពុងឋិតនៅកន្លែងណា? ឬយកល្អ អ្នកឯងទៅយកវាមកដាក់នៅកន្លែងចាស់ឱ្យយើងវិញ យកឱ្យទាន់ក្នុងពេលឥឡូវ កុំចាំដល់ស្អែក ។

ទេពចម្លែកគ្រវីក្បាល :

- វិមានរបស់ចៅហ្វាយម្ចាស់កំពុងឋិតនៅខាងទ្វីបអាហ្វ្រិកឯណោះ ប៉ុន្តែការងារយកមកវិញមិនមែនសមត្ថកិច្ចរបស់ខ្ញុំទេ វាជាសមត្ថកិច្ចរបស់ទេពចង្កៀងទិព្វ ។

អាឡាដាំងសញ្ជឹងគិតបន្តិច រួចនិយាយ :

- បើអ៊ីចឹងយើងបញ្ជាអ្នកឯងនាំយើងទៅកន្លែងដែលមានវិមានទោះកន្លែងនោះនៅដល់ជើងមេឃណាក៏ដោយ ហើយដាក់យើងឱ្យចំកន្លែងក្រោមបង្អួចបន្ទប់រាជធីតាបាឌ្រូប៊ូឌួ ។

ស្ទើរតែនាយនិយាយអស់ពាក្យពីមាត់សឹងមិនទាន់ ទេពចម្លែកលើកហោះវឹ ! សំដៅទ្វីបអាហ្វ្រិកលឿនដូចព្រួញរបូតពីខ្សែធ្នូ ពេលទៅដល់វាលមួយដែលវិមានដ៏ស្កឹមស្កៃកំពុងឋិតជ្រងោ គាត់ដាក់នាយចុះចំខាងក្រោមបង្អួចបន្ទប់រាជធីតា ។ កិច្ចការនេះចំណាយពេលតែប៉ុន្មានដង្ហើមប៉ុណ្ណោះ ។

ថ្វីបើយប់ងងឹតក៏អាឡាដាំងអាចមើលស្គាល់វិមានរបស់ខ្លួននិងបន្ទប់ដោយខ្សៀករបស់រាជធីតា ។ ប៉ុន្តែដោយខាងក្នុងវិមានស្ងាត់

ច្រៀបតាមមើលមនុស្សម្នាដេកលក់អស់ នាយក្តាប់សភាពការណ៍មិនទាន់បានក៏សម្រេចចិត្តរកកន្លែងសម្រាកសិន ចាំភ្លឺឡើងសឹមគិតទៀត។ នាយថយទៅអង្គុយក្រោមដើមឈើមួយ ដែលអាចមើលវិមានឃើញច្បាស់ ។ ពីទីនោះនាយសម្លឹងអច្ឆរិយវត្ថុដ៏អស្ចារ្យរបស់ខ្លួនជាមួយអារម្មណ៍ធូរស្រាលច្រើន បើប្រៀបធៀបកាលប៉ុន្មានថ្ងៃមុន, រួចមួយសន្ទុះក្រោយក៏ប្រះខ្លួនលើស្មៅដេកយកកម្លាំងបន្ទាប់ពីនឿយហត់យូរថ្ងៃ ។

ស្អែកឡើងអាឡាដាំងក្រោកពីព្រលឹមស្រាង១ ដើរទៅឈរក្រោមបង្អួចរាជធីតា ដើម្បីឱ្យអ្នកខាងលើមើលចុះឃើញ ។ ឆ្លៀតពេលនេះ នាយពិចារណារកមូលហេតុដែលនាំដល់សភាពការណ៍ក្រឡាប់ចាក់, គិតចុះគិតឡើងរកឃើញយ៉ាងងាយថាមកពីខ្លួនឃ្លាតឆ្ងាយចង្កៀងទិព្វ, បើទៅណាមួយជំហ៊ានក៏យកតាម ម្ល៉េះពុំមានឧប្បត្តិហេតុអាក្រក់ដូច្នេះឡើយ ។ ប៉ុន្តែប្រការដែលពិបាកយល់ក្នុងរឿងនេះគឺអ្នកណាឈ្នានីសខ្លួន, ឬក៏....

នាយព្រឺខ្លួនខ្វាកនៅពេលចាប់ភ្លឹកគ្រូធ្មប់អាហ្វ្រិក !

អាឡាដាំងកំពុងឈរគិត ស្រាប់តែភីលៀងម្នាក់របស់រាជធីតាអើតក្បាលតាមបង្អួច ។ ដំបូងនាងស្មានខ្លួនឯងព្រិលភ្នែក ខំព្រិចពីរបីដង, លុះជឿជាក់អ្នកឈរខាងក្រោមជាអាឡាដាំងមែនក៏រត់ត្រហេបត្រហបទៅថ្វាយដំណឹងដល់រាជធីតា ។



តាំងពីថ្ងៃត្រូវចាប់នាំមកទ្វីបអាហ្វ្រិក រាជធីតាបាត្រុនប៊ូឌូផ្ទុំពុំបានលក់ស្រួលឡើយ ហើយតែងតើនពីព្រលឹមគង់សំកុកសោកសង្រេងមួយអង្គឯង ស្រណោះនគរ ស្រណោះមាតាបិតានិងប្តីសម្លាញ់។ ព្រឹកនេះរាជធីតាទើបតែយាងចុះពីលើគ្រែល្មមពេលភីលៀងចូលដល់ផ្តល់ព័ត៌មានរំភើប ។ ព្រះនាងប្រញាប់ប្រញាល់ស្ទុះទៅអើតមើលផ្ទាល់ហើយធ្វើសញ្ញាផង មានបន្ទូលពីលើចុះផង : "បងចាំបន្តិចណា៎, អូនឱ្យគេចុះទៅបើកទ្វារសម្ងាត់" ។

ទ្វារសម្ងាត់នោះឋិតចំខាងក្រោមបន្ទប់រាជធីតា, គ្រាន់តែទ្វារបើកភ្លាមអាឡាដាំងឡើងត្រង់ទៅលើតែម្តង ។

ការជួបគ្នារវាងស្វាមីភរិយា ដែលមុននេះស្មានថាព្រាត់ជារៀងរហូតនោះ គ្មាននរណាអាចព័ណ៌នាបានពីទំហំរំភើបរីករាយរបស់គេឡើយ ។ អ្នកទាំងពីរហូរទឹកភ្នែករហាមឱបរឹតគ្នាយ៉ាងយូរ ។ មួយសន្ទុះធំទើបគេលារង្វង់ដៃសម្រួតខ្លួនអង្គុយលើកៅអី ហើយអាឡា-ដាំងផ្តើមនិយាយមុន :

- រាជធីតា ! ដំបូងបង្អស់សូមប្រាប់បងសិន តើចង្កៀងរបស់បងលាក់លើចុងសសរក្នុងសាលទទួលភ្ញៀវនោះឥឡូវទៅណាហើយ?

ឮសួររឿងនេះរាជធីតាយំសស្រាក់ បន្លឺទាំងអួលណែន :

- បងសម្លាញ់ ! ប៉ុន្មានថ្ងៃហើយ អូនចេះតែមានអារម្មណ៍សង្ស័យគ្រោះថ្នាក់របស់យើងទាំងពីរនាក់ប្រហែលចេញពីប្រភពចង្កៀង





នោះ, ហើយប្រការដែលធ្វើឱ្យអូនឈឺចាប់បំផុត គឺអូនជាអ្នកបង្កឡើង ។

អាឡាដាំងលួងលោមសម្រាលទុក្ខសោកប្រពន្ធ :

- ទេ ! មួយចំណែកធំគឺមកពីបង, គួរណាស់បងយកជាប់តាមខ្លួនរហូត ។ ប៉ុន្តែណើ្តយ, ពេលនេះយើងពិគ្រោះគ្នារកមធ្យោបាយដោះស្រាយវិញ ។ ដំបូងបង្អស់ សូមរាជធីតារ៉ាយរ៉ាប់ពីហេតុការណ៍កន្លងមក តើអ្វីខ្លះបានកើតឡើងដែលនាំដល់គ្រោះថ្នាក់ដូច្នេះ?

រាជធីតាបាឌ្រុនប៊ូឌួរៀបរាប់ហូរហែពីករណីតាចាស់ម្នាក់ដើរពពាយនាយដូរចង្កៀងថ្មីយកចង្កៀងចាស់, ព្រះនាងចង់កំប្លែងលេងតើគេឆ្កួតមែនឬយ៉ាងណាក៏ឱ្យទាសករឡើងយកចង្កៀងពីចុងសសរដូរជាមួយគេ. លុះយប់ឡើងស្រាប់តែទទួលអារម្មណ៍ហាក់ដូចវិមានទាំងមូលធ្វើចលនា រួចក៏ឃើញមកឋិតនៅទ្វីបអាហ្វ្រិកតែម្តង ។ ព្រះនាងបញ្ជាក់ថា គឺតាចាស់បន្លំខ្លួនដើរដូរចង្កៀងជាអ្នកបង្កើតអព្ភូតហេតុនេះ ព្រោះគេបានអូតប្រាប់ព្រះនាងត្រង់ៗ បន្ទាប់ពីអ្វីៗធ្លាក់ក្នុងកណ្តាប់ដៃគេ ។

អាឡាដាំងនិយាយកាត់ :

- ព្រះរាជធីតាបង្ហើបប៉ុណ្ណេះ បងដឹងជននោះជានរណាហើយ ។ គេជាប្រភេទមនុស្សដូចម្តេច ចាំពេលក្រោយបងនិយាយប្រាប់ ។ ឥឡូវបងចង់ដឹងតែម្យ៉ាង គឺចង្កៀងនោះសព្វថ្ងៃនៅឯណា?

- ជនឃោរឃៅខ្ចប់ទុកក្នុងខ្លួនវាយ៉ាងប្រយ័ត្នប្រយែងបំផុត,

(រាជធីតាតប) អូនបានអះអាងដូច្នេះ ព្រោះវាធ្លាប់យកចេញពីខ្លួនលាកញ្ចប់ឱ្យអូនមើល ។

- តាំងពីថ្ងៃនោះវាមានអាកប្បកិរិយាជាមួយរាជធីតាដូចម្ដេចដែរ?

- មួយថ្ងៃវាមកលួងលោមអូនម្ដង, រយៈពេលប្រហែលមួយម៉ោង, តែដោយលើកណាក៏បានទទួលពាក្យប្រមាថមើលងាយជូរចត់ វាអត់ទាន់បានរំខានយូរ ហើយក៏មិនដែលបានមកពីរដង ឬបីដងក្នុងមួយថ្ងៃដែរ ។ តាមមើលទៅវាមានបំណងប្រើមធ្យោបាយត្រជាក់ អូសទាញសិន ។ រាល់លើកមករកអូន វានិយាយដដែល១ អង្វរអូនឱ្យឈប់នឹកនាបង, ព្រមទទួលវាជាប្ដី ។ វាខំបញ្ចុះបញ្ចូលអូនឱ្យជឿថា ជាតិនេះគ្មានសង្ឃឹមជួបបងវិញទេ, បងត្រូវព្រះបិតាអូនប្រហារជីវិតហើយ ។ ជាមួយគ្នានេះ វាជេរបងមនុស្សរមិលគុណ ។ វាថាភាពរុងរឿងរបស់បងគឺដោយសារវា ។ វានិយាយច្រើនណាស់ តែអូនមិនរវល់មើលមុខវា។ ទីបំផុត វាត្រូវបង្ខំចិត្តត្រឡប់ក្រោយទាំងស្រពោន។ ប៉ុន្តែអូននៅតែមានអារម្មណ៍ថាមិនយូរមិនឆាប់វាមុខជាប្រើធមិក្ដៅ។ វិញ ព្រោះអូននៅក្នុងកណ្ដាប់ដៃវាស្រាប់ ។ បងពិតជាមកទាន់ពេលល្អណាស់ បើនៅយូរបន្តិចទៀត អូនមានគ្រោះថ្នាក់ដោយសារវាមិនខាន ។

- កុំបារម្ភ, (អាឡាដាំងអះអាង) បងនឹកឃើញមធ្យោបាយ



ដោះស្រាយជាមួយជនឃោរឃៅហើយ ។ ប៉ុន្តែកិច្ចការនោះចាំបងមកពីផ្សារសិន ។ បងត្រូវទៅផ្សារឥឡូវ ប្រហែលថ្ងៃត្រង់ទើបចាត់ចែងសព្វគ្រប់ ។ ពេលត្រឡប់មកវិញបងមកក្នុងសំលៀកបំពាក់ផ្សេង។ រាជធីតាតោងចាត់មនុស្សឱ្យនៅប្រចាំការត្រង់ទ្វារសម្ងាត់ ដើម្បីសំរួលដល់ការចេញចូលរបស់បង ។

ផ្ដែផ្ដាំសព្វគ្រប់ហើយ,អាឡាដាំងចេញពីវិមានតាមទ្វារសម្ងាត់។ ពេលមកដល់ខាងក្រៅ នាយអើតឆ្វេងស្ដាំអត់ឃើញមានអ្វីគួរសង្ស័យក៏ដើរតម្រង់ទៅវាលស្រែ ។ នៅទីនោះជួបកសិករម្នាក់ នាយស្នើដូរខោអាវជាមួយគេ, សុខចិត្តឱ្យខោអាវល្អរបស់ខ្លួនទៅគេ ។ ស្លៀកពាក់រៀបចំខ្លួនរួច នាយបំបែរដំណើរទៅផ្សារ រកទិញថ្នាំពុលធុនខ្លាំងកន្លះនាឡិ, ស្រេចបាច់ហើយ ស្រូតរូតត្រឡប់មកវិមានវិញ ។

អាឡាដាំងមិនពិបាកចេញចូលឡើយ ព្រោះមានអ្នកបម្រើត្រៀមចាំត្រង់ទ្វារសម្ងាត់ជយយសម្រួលដំណើរ ។ ពេលឡើងដល់លើ នាយលាកញ្ចប់បង្ហាញរាជធីតា :

- នេះជាថ្នាំពុលធុនខ្លាំងបំផុត, រាជធីតាយល់បំណងបងទេ?

រាជធីតាញញឹម :

- អូនយល់ហើយ, វិធីនេះពិតជាជួយរំដោះយើងពីគ្រោះថ្នាក់បាន ។

- ចាប់ពីឥឡូវទៅ រាជធីតាជាអ្នកដើរតួ, (អាឡាដាំងបញ្ជាក់

ថែម) បងគិតសព្វគ្រប់ហើយ មានតែមធ្យោបាយហ្នឹងមួយគត់ ។ ដំបូងបំផុតរាជធីតាត្រូវផ្លាស់សម្លៀកបំពាក់ប្រណីត និងតុបតែងខ្លួនឡើងវិញ. ពេលគ្រូធ្មប់មកដល់ រៀបឫកពារាក់ទាក់ទទួលវា ធ្វើដូចខ្លួនឯងប្ដូរចិត្តគំនិតលែងនឹកនារឿងចាស់ទៀត ។ កាលបើធ្វើឱ្យវាជឿស៊ប់បានហើយ តោងស្នើអញ្ជើញវាបាយទឹកជាមួយគ្នាក្នុងវិមានម្ដង រួចឆ្លៀតពេលនោះនិយាយថា ចង់ស្គាល់រសជាតិស្រាឆ្ងាញ់ខាងទ្វីបអាហ្វ្រិក. ឮដូច្នោះវាពិតជាប្រញាប់ប្រញាល់លារាជធីតាដើម្បីទៅយកស្រាមកបំពេញបំណងស្រីស្រស់ ។ មនុស្សដូចវាមិនខ្វះស្រាប្រភេទឆ្ងាញ់ទេ ។ គឺពេលនោះហើយដែលរាជធីតាត្រូវបង់ថ្នាំពុលចូលកែវមួយទៀតដូចកែវរបស់ខ្លួនកំពុងកាន់ ។ កុំភ្លេចផ្ដាំទាសីទទួលភារកិច្ចចាក់ស្រា. ពេលឃើញសញ្ញាតោងចាក់ចូលកែវដែលមានថ្នាំពុល ហើយយកមកផ្ទាល់ដៃ។ ការងារនេះតោងរហ័សរហួនបំភាន់ផ្នែកជនឃោរ-ឃៅ កុំឱ្យវាដឹងរឿងដូរកែវ. លោតែបែកការណ៍ពិតជាស្លាប់ទាំងអស់គ្នាមិនខាន ។ បន្ទាប់មករាជធីតាធ្វើជាលើកកែវឡើងសុំដូរកែវតាមបែបគួរស្នេហ៍ភាគច្រើនខាងនគរយើង តែធ្វើដើម្បីសម្ដែងទឹកចិត្តស្មោះស្ម័គ្រទៅវិញទៅមក ។ បងជឿថាដាច់ខាតវាអត់ហ៊ានប្រកែក. មិនតែប៉ុណ្ណោះបន្ទាប់ពីទទួលកែវស្រារបស់រាជធីតា វានឹងប្រញាប់ប្រញាល់ផឹកទាល់តែអស់រលីង. ខំស្រួតបង្ហើយដោយនឹកថា កាន់តែឆាប់អស់កាន់តែល្អ ដែលតាមពិតគឺកាន់តែឆាប់អស់កាន់តែឆាប់ងាប់ ។



រាជធីតាបាទ្រប៊ូឌូឆ្លើយដោយអត់វារែក :

- ដើម្បីសេចក្ដីសុខរបស់យើងទាំងពីរនាក់ ក៏ដូចដើម្បីកំចាត់ជនឃោរឃៅពីផែនដី អូននឹងខិតខំបំពេញការងារនេះឱ្យបានល្អបំផុត ។

ពិភាក្សាគ្នាសព្វគ្រប់ហើយ អាឡាដាំងក៏រកកន្លែងសម្ងំលាក់ខ្លួនដើម្បីតាមដានការវិវត្តបន្ត ។ រាជធីតាបាទ្រប៊ូឌូប្រញាប់ប្រញាល់យាងទៅសម្អាងកាយរៀបចំដើរតួថ្មី ។ តាំងពីថ្ងៃវិមានត្រូវរំកិលមកទ្វីបអាហ្វ្រិកដោយសារចាញ់កលជនឃោរឃៅនេះជាលើកដំបូងបំផុតដែលព្រះនាងតុបតែងខ្លួន ។

ចំណែកគ្រូធ្មប់អាហ្វ្រិក ថ្ងៃនោះដូចសព្វដងដែរ គ្រាន់តែព្រះអាទិត្យជ្រេទាបបន្តិចធ្វើដំណើរមកវិមានអាឡាដាំងទៀត ដើម្បីលួងលោមរាជធីតាឱ្យបំភ្លេចរឿងចាស់ បែរមកស្ម័គ្រមេត្រីជាមួយខ្លួនវិញ។ តាមផ្លូវ គាត់ខំរៀបពាក្យសម្ដីហើយស្រេច ខ្លាចក្រែងជួបកាយវិការគម្រោះគម្រើយដូចមុន ដឹងអីឡើងដល់សាលទទួលភ្ញៀវ ស្រាប់តែអ្វីៗប្រែប្រួលផ្ទុយពីសព្វដង ដោយរាជធីតាញញឹមយ៉ាងស្រស់ដាក់គាត់ មិនតែប៉ុណ្ណោះព្រះនាងសម្អាងកាយឃើញដូចទេពអប្សរចុះក្រ-សាលកណ្ដាលឧទ្យាន។ គាត់ច្រួលច្របល់ភាន់ភាំងអស់ជាច្រើនដង្ហើមសឹងមិនហ៊ានជឿថានេះជាការពិត ។ គាត់ឈរឆ្ងឹងពុំដឹងត្រូវចាប់ផ្ដើមនិយាយយ៉ាងណាឱ្យសម ។

រាជធីតាញញឹមកាន់តែស្អាត. ព្រះនាងក្រោកឡើងអញ្ជើញគ្រូ

ធ្មប់អាហ្វ្រិកអង្គុយលើកៅអីនៅទល់មុខ រួចមានបន្ទូលស្រាលៗ :

- ប្រហែលលោកនឹកចម្លែកនឹងអាកប្បកិរិយាខ្ញុំចំពោលលោក ដែលខុសប្លែកពីថ្ងៃមុន ប៉ុន្តែលោកនឹងបានជ្រាបច្បាស់កាលបើដឹងថា ខ្ញុំជានារីម្នាក់មិនចូលចិត្តព្រួយយូរ នឹកនាយូរ ខ្វល់ខ្វាយយូរ, អ្វីៗកន្លងផុត បើគ្មានលទ្ធផលដោះស្រាយទេ ខ្ញុំស្រពាប់ស្រពោនមួយរយៈក៏ខំបំភ្លេចវាចោលដោយឯកឯង។ ខ្ញុំបានពិចារណាច្រើនពីសម្ដីលោកដែលនិយាយពីវាសនាអាឡាដាំង។ ម្យ៉ាងទៀតដោយធ្លាប់យល់ចរិតឆេវឆាវរបស់ព្រះបិតាខ្ញុំផង ខ្ញុំត្រូវតែទទួលស្គាល់ថាអាឡាដាំងទៀងពីត្រូវទទួលទោសប្រហារជីវិត ។ ចំណែកព្រះបិតាខ្ញុំក៏បានត្រឹមតែប្រហារជីវិតអាឡាដាំងប៉ុណ្ណោះ ពុំអាចជួយខ្ញុំបាន ព្រោះព្រះអង្គមិនដឹងខ្ញុំនៅទីនេះ តែបើទុកជាដឹងក៏គ្មានលទ្ធភាពដោះស្រាយ ។ អ៊ីចឹងខ្ញុំយំសោកតទៅទៀតបានការអី ។ យល់ដូច្នេះ ទើបបន្ទាប់ពីសម្ដែងកាយវិការកាន់ទុក្ខអស់រយៈពេលកន្លងមក ដើម្បីឱ្យសក្តិសមនិងពាក្យប្ដីប្រពន្ធពេញច្បាប់, ខ្ញុំគិតថាត្រូវតែធ្វើខ្លួនឱ្យវិលមករកការសប្បាយក្នុងជីវិតមួយថ្មីលើទឹកដីដែលខ្លួនមិនធ្លាប់ស្គាល់។ គឺការសម្រេចចិត្តនេះឯងដែលធ្វើឱ្យលោកឃើញនូវកាយវិការចម្លែកគួរឱ្យភ្ញាក់ផ្អើល ។ ខ្ញុំប្ដេជ្ញាចិត្តឈប់នឹកនារឿងចាស់រហូត ។ លោកជួយឱ្យការសម្រេចចិត្តរបស់ខ្ញុំទទួលជោគជ័យផង, ជួយឱ្យជីវិតខ្ញុំបានស្រស់បំព្រងឡើងវិញ ។ យប់នេះខ្ញុំចង់អញ្ជើញលោកចូលរួមបាយទឹកជាមួយខ្ញុំមួយពេល ដើម្បីឱ្យខ្ញុំ



មានគ្នានិយាយលេងបន្ទប់ទុក្ខ ។ សង្ឃឹមថាលោកទទួលយល់ព្រមដោយរីករាយ ព្រោះលោកពិតជាចង់ឃើញខ្ញុំសើច មិនចង់ឃើញខ្ញុំស្រពាប់ស្រពោនទេ។ ខ្ញុំនឹងចាត់ទាសាទាសីរៀបម្ហូបអាហារពិសេសៗជូនលោក។ ប៉ុន្តែខ្ញុំសូមជម្រាបត្រង់ថា ដោយហេតុក្នុងវិមានទាំងមូលសុទ្ធតែស្រាចិន ឯខ្លួនឯងកំពុងរស់នៅលើទឹកដីអាហ្វ្រិក ខ្ញុំស្រាប់តែកើតគំនិតមួយចង់ភ្លក្សស្រាអាហ្វ្រិកម្ដង។ ចង់ឱ្យពេលបាយនេះកំដរដោយស្រាឆ្ងាញ់ខាងអាហ្វ្រិក, បើលោកមិនប្រកាន់គំនិតនេះនាំអំពល់ទុក្ខដល់លោកទេ សូមជួយដោះស្រាយមួយពេល ។

គ្រូធ្មប់អាហ្វ្រិកថ្វីបើធ្លាប់រឹងប៉ឹងនៅចំពោះមុខរាល់ហេតុការណ៍តូចធំ តែម្ដងនេះបែរជាជ្រាយល្ហកល្ហេវក្លាយជាមនុស្សទន់ខ្សោយបំផុត, គិតតែងក់ក្បាលធានាអះអាង ។ គាត់អួតថាស្រាដែលល្បីជាងគេនៅទ្វីបអាហ្វ្រិក គឺស្រាចេញពីតំបន់គាត់កំពុងរស់នៅសព្វថ្ងៃ, ហើយ ប្រភេទលេខមួយនោះ គាត់មានពីរដបរក្សាទុកតាំងពីប្រាំពីរឆ្នាំមុន អត់ទាន់ប៉ះពាល់នៅឡើយ, អាចថាពីរដបនោះ ជាមួយរយៈពេលផ្អាប់ទុកយូរដូច្នេះ សព្វថ្ងៃវាក្លាយជាស្រាឆ្ងាញ់ដាច់គេមួយផែនដីក៏ថាបាន។ “បើរាជធីតាអនុញ្ញាត, (គាត់និយាយបន្ត) ខ្ញុំធានាទៅយកមកថ្វាយក្នុងពេលឥឡូវ ដើម្បីឱ្យពេលបាយប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយ” ។

- ខ្ញុំមិនហ៊ានរំខានលោកទេ, (រាជធីតាតប) លោកគួរប្រើអ្នកផ្សេងទៅយក, ចាំបាច់អីអំពល់ទុក្ខខ្លួនឯង ។

- គ្រាន់តែប៉ុណ្ណឹងរំខានអី. (គ្រូធ្មប់អាហ្វ្រិកប្រកែក) ម្យ៉ាងទៀតកូនសោឃ្លាំងពិសេសរបស់ខ្ញុំ គ្មាននរណាដឹងខ្ញុំលាក់ទុកកន្លែងណាទេ. បើទុកជាដឹងក៏មិនចេះបើកដែរ ។

ជាមួយអារម្មណ៍ពុះកញ្ជ្រោលក្នុងសុភមង្គលដែលគាត់ស្មានថាទេវតាប្រទានដោយចៃដន្យនេះ។ និយាយរួចគ្រូធ្មប់អាហ្វ្រិកសឹងថាមិនមែនរត់ទេ គឺហោះតែម្តង ដើម្បីទៅយកស្រាឆ្ងាញ់លេខមួយផ្អាប់ទុកប្រាំពីរឆ្នាំផ្គាប់ចិត្តស្រីស្រស់។ ដំណើររបស់គាត់ស្រាលខុសសព្វដងឃើញដូចរអិលលើចុងស្មៅ ។ គាត់ចេញទៅមិនដល់កន្លះម៉ោងផងត្រឡប់មកវិញភ្លាម ។

រាជធីតាដឹងមុនថា ជនឃោរឃៅទៅមិនយូរ ព្រះនាងម្ចីម្ចាចាត់ចែងបង់ថ្នាំចូលកែវ រួចលាក់ក្នុងកន្សែតមួយ ត្រៀមចាំឱកាសល្អអាលធ្វើសញ្ញាប្រាប់ទាសីឱ្យយកកែវនោះចេញប្រើ ។ ពេលគ្រូធ្មប់មកដល់ ព្រះនាងអញ្ជើញគាត់អង្គុយលើកៅអីមួយទល់មុខ ធ្វើឱ្យគាត់ត្រូវបែរខ្នងទៅរកទូស្រា រួចព្រះនាងញញឹមឡើង :

- ពេលបាយរបស់យើងអាចចាប់ផ្តើមបានហើយ ប៉ុន្តែមិនចង់ឱ្យពេលបាយនេះមានតន្ត្រីកំដរដូចសព្វដង ព្រោះខ្ញុំយល់ថា ដោយហេតុមានតែយើងពីរនាក់ គួររក្សាបរិយាកាសស្ងប់ស្ងាត់ដើម្បីនិយាយគ្នាលេងប្រសើរជាង ។ ខ្ញុំត្រូវការបន្ទប់ទុក្ខតាមរយៈការសំណេះសំណាលស្និទ្ធស្នាល ។



គ្រូធ្មប់អាហ្វ្រិកស្មានថារាជធីតាចាប់ផ្តើមឱ្យដៃមែនទែន រីតតែត្រហេបត្រហបយល់ព្រមតាម. មាត់សើចស្ញេញស្ញាញចេញធ្មេញរកេតរកូតគួរឱ្យខ្ពើម ។

បាយទឹកបានពីរបីម៉ាត់ រាជធីតាបញ្ជាទាសីឱ្យចាក់ស្រាដែលគ្រូធ្មប់អាហ្វ្រិកយកមក ។ ព្រះនាងលើកកែវជូនពរសុខភាពភ្ញៀវ រួចសោយអស់រលីង សោយរួចធ្វើជាសរសើរ :

- លោកមានប្រសាសន៍អត់ខុសមែន. ស្រានេះឆ្ងាញ់អស្ចារ្យណាស់ ខ្ញុំសូមប្រកាសថាលើផែនដីពុំអាចរកស្រាណាប្រដូចជាមួយវាបាន ។

គ្រូធ្មប់អាហ្វ្រិកបង្ហើយស្រាពីកែវ ព្រមទាំងឆ្លើយតប :

- សូមថ្លែងអំណរគុណដោយក្តីគោរពចំពោះការសរសើររបស់ព្រះនាង ។

លុះការហុបចុកបន្តបានមួយសន្ទុះទៀត ឯស្រាក៏ត្រូវបានចាក់ថែមបួនប្រាំដង រាជធីតាសម្គាល់ឃើញជនឃោរឃៅកាន់តែបង្ហាញភាពស្រេកឃ្លានខ្លាំងឡើង ក៏ចាប់ផ្តើមធ្វើសញ្ញាដល់ទាសីទទួលភារកិច្ចចាក់ស្រា. ទន្ទឹមនឹងការធ្វើសញ្ញាសម្ងាត់នេះ ព្រះនាងធ្វើជាបញ្ជាខ្លាំងៗ ឱ្យចាក់ស្រាពេញកែវភ្ញៀវ និងកែវព្រះនាង ។ ទាសីត្រៀមមុនហើយស្រេច ឃើញសញ្ញាភ្លាមម្ចីម្ចាបន្លំដូរកែវដែលមានបង់ថ្នាំពុលហើយ ចាក់ស្រាតាមបញ្ជា ។

ធីតាលើកកែវមានថ្នាំពុល តម្រង់ទៅរកភ្ញៀវ :

- ដោយហេតុថ្មីថ្មោងពេក ខ្ញុំពុំទាន់បានដឹងតើខាងទ្វីបអាហ្វ្រិក គូសង្សារបង្ហាញទឹកចិត្តដាក់គ្នារបៀបម៉េចទេ. តែបើនៅខាងប្រទេស ខ្ញុំសង្សារចិត្តមួយថ្លើមមួយ ពិសេសសង្សារថ្មីថ្មោងចាំបាច់ត្រូវតែប្តូរកែវគ្នា ដើម្បីជូនពរសុខភាពទៅវិញទៅមក និងជានិមិត្តរូបឧទ្ទិសដល់សេចក្តីស្នេហារបស់គេ សូមឱ្យគេគង់វង្សត្រជាក់ត្រជុំជានិច្ចនិរន្តរ៍ ។

មានបន្ទូលចប់ភ្លាម ព្រះនាងហុចកែវស្រាឱ្យភ្ញៀវ ដំណាលពេលព្រះហស្តស្តាំលាចាំទទួលកែវស្រារបស់ភ្ញៀវ ។

គ្រូធ្មប់អាហ្វ្រិកគ្មានសង្ស័យអ្វីប៉ុនសរសៃសក់ឡើយ ស្មានតែរាជធីតាស្ម័គ្រប្រគល់បេះដូងមែន. ឱកាសដ៏ល្អនេះនឹងនាំដល់ឋានសួគ៌នៅពេលចប់ការជប់លៀងជាមិនខាន ។ គាត់ក្តៅមុខក្តៅមាត់ទទួលកែវស្រាពីរាជធីតា ហើយប្រគល់កែវស្រារបស់ខ្លួនឱ្យរាជធីតាវិញ, កាយវិការរញ៉ីរញ៉ូរឃើញគួរឱ្យខ្ពាញ់ក្រៃលែង ។ បន្ទាប់នោះ គាត់លើកកែវស្រាឡើងនិយាយ :

- រាជធីតាដ៏ប្រិមប្រិយអើយ ! ខ្ញុំសូមសារភាពជនជាតិអាហ្វ្រិកយើងខ្ញុំសឹងគ្រប់សាសន៍ ពុំបានជ្រៅជ្រះវិស័យមនោសញ្ចេតនាស្នេហាប្រហែលជនជាតិចិនទេ ។ ពេលនេះទន្ទឹមនឹងរៀនសូត្របានមេរៀនមួយដ៏ល្អប្រសើរ ខ្ញុំថែមទាំងបានទទួលអំណោយថ្លៃថ្លាពីព្រះនាងផង ។ រាជធីតាអើយ ! ផឹកអស់ស្រាក្នុងកែវព្រះនាងប្រទាន



ដោយផ្ទាល់ បានសេចក្តីថាជីវិតខ្ញុំស្រស់បំព្រងឡើងវិញ បន្ទាប់ពីអស់សង្ឃឹមស្វិតស្រពោនបួនប្រាំថ្ងៃដោយសារការបដិសេធរបស់ព្រះនាង ។ សូមទទួលថ្វាយតាមត្រង់. ខ្ញុំកំពុងទទួលអារម្មណ៍ថា ជីវិតខ្ញុំមានន័យជាងពេលណាៗទាំងអស់ ។

រាជធីតាធុញថប់សឹងដាច់ខ្យល់ ចំពោះសម្តីយកចិត្តយកថ្លើមនេះ ព្រះនាងបន្លឺកាត់ :

- សូមលោកពិសាឱ្យអស់សិនសឹមមានប្រសាសន៍បន្ត. យើងមានពេលនិយាយគ្នាច្រើនតទៅទៀត ។ ខ្ញុំចង់ឱ្យពេលបាយនេះបន្លាយយ៉ាងតិចពីរម៉ោង ។

ចប់វាចា ព្រះនាងធ្វើជាលើកកែវប្រុងសោយ ។ ឃើញដូច្នេះ គ្រូធ្មប់អាហ្វ្រិកម្ចីម្ចាផឹកក្អេកៗ ស្រូតបង្ហើយឱ្យបានមុនដៃគូ ។ ផឹករួចគាត់ងើយក្បាលមកក្រោយបន្តិច ដើម្បីបង្ហាញថាខ្លួនបញ្ចប់កែវស្រាប្តូរបេះដូងហើយ អត់មានសល់មួយដំណក់ទេ. តែភ្លាមនោះដែរ ស្រាប់តែគាត់បញ្ឈរភ្នែកសស្កុះ ដងខ្លួនញាក់តាត់ៗ រួចរលំគ្រេងលើកម្រាលដោយអត់ទាន់និយាយបានអ្វីមួយម៉ាត់ ។

អាឡាដាំងកំពុងសម្ងំចាំខាងក្រោយ ទទួលឃើញទាសករម្នាក់ទៅដល់ប្រាប់ថាការងារបានទទួលជោគជ័យហើយ ក៏ប្រញាប់ប្រញាល់រត់ឡើងសាលទទួលភ្ញៀវ ស្ទុះចូលឱបថើបរាជធីតាដោយក្តីរំភើប :

- បងសូមសរសើរដោយស្មោះចំពោះភាពប៉ិនប្រសប់ដើរតួរបស់

រាជធីតា ។ ប្រសិនបើអ្នកណាផ្សេងប្រហែលជាមិនងាយបោកប្រាស់ជនឃោរឃៅនេះបានទេ ។

រាជធីតាសួរដេញដោល :

- ឥឡូវយើងធ្វើម៉េចទៀត ?

- បន្ទាប់ពីនេះសូមរាជធីតាចុះទៅបន្ទប់ខាងក្រោម ហើយហៅអ្នកឯទៀតចុះតាមទាំងអស់ ដើម្បីបងធ្វើកិច្ចការនាំរាជធីតាត្រឡប់ទៅនគរវិញ ។

រាជធីតាសែនត្រេកអរដែលឮថាបានត្រឡប់ទៅនគរវិញ ព្រះនាងប្រញាប់ប្រញាល់នាំទាសករទាំងអស់ចុះទៅជាន់ក្រោមតាមសំនូមពរប្តី ។

នៅតែម្នាក់ឯង, អាឡាដាំងដើរសំដៅសពគ្រូធ្មប់អាហ្វ្រិកដែលដេកស្លាប់បើកភ្នែកគ្រលូង លូកយកចង្កៀងទិព្វចេញពីខ្លួនគាត់ហើយជុសម្រាមដៃស្រាលល្មមដូចដែលធ្លាប់អនុវត្តកន្លងមក ។ ពេលទេពចម្លែកបង្ហាញខ្លួនសួរនូវសំនួរដដែល នាយចេញបញ្ជា :

- អ្នកឯងត្រូវធ្វើការងារមួយជាបន្ទាន់ គឺយកវិមាននេះទៅដាក់នៅកន្លែងដើម យកមកតាមរបៀបណា ឥឡូវយកទៅវិញតាមរបៀបនោះ ។

ទេពចម្លែកឱនក្បាលសម្តែងកាយវិការកោតក្រែង រួចបំបាំងខ្លួនបាត់ ។ ប៉ុន្តែទន្ទឹមនឹងការបាត់ខ្លួនទេពចម្លែក ស្រាប់តែអ្នកផង



ទទួលអារម្មណ៍ហាក់ដូចវិមានទាំងមូលកម្រើក១ក្នុងចលនាហោះហើរ ។ នេះជាការទទួលអារម្មណ៍លើកទីពីរ បន្ទាប់ពិលើកដំបូងដែលភ្លឺឡើងម្នាក់១ស្រឡាំងកាំង ដោយឃើញកំពុងស្ថិតនៅលើទីក្រុងដីផ្សេង ។ មែន ! វិមានកំពុងហោះហើរលឿនស្ទើរកណ្តាលអាកាសវេហាស៍ លឿនដល់ថ្នាក់គ្រាន់តែប៉ុន្មានដង្ហើមក្រោយប៉ុណ្ណោះ មកដល់កន្លែងដើមវិញ ។

អាឡាដាំងបំពេញកិច្ចការរួច ក៏ចុះមកជាន់ក្រោម ស្ទុះឱបថើបរាជធីតាដោយក្តីអំណរដ៏លើសលប់ ពេលរាជធីតាកំពុងយាងចេញពីបន្ទប់ ។ បន្ទាប់នោះនាយអះអាងដើម្បីរម្ងាប់ការបារម្ភរបស់ភរិយា

- ចាប់ពីថ្ងៃនេះទៅគ្មាននរណាបៀតបៀនយើងបានទៀតទេ ។ រាជាធីតាសុបិនអាក្រក់នោះចោលទៅ ដើម្បីព្រឹកឡើងយើងបានទទួលព្រះបិតាព្រះមាតាក្នុងអាការៈហាក់ដូចគ្មានប្រែប្រួលអ្វីសោះ ។

ដោយហេតុអម្បាញ់មិញរាជធីតាបាឡ្រប៊ូឌ្មពុំទាន់សោយឆ្អែត ចំណែកអាឡាដាំងក៏ពុំទាន់បាយទឹកនៅឡើយ ។ បន្ទាប់ពីការសប្បាយរីករាយ ព្រោះឆ្លងផុតគ្រោះថ្នាក់ រាជធីតាបញ្ជាឱ្យគេរៀបបាយទឹកម្តងទៀត ហើយសោយយ៉ាងសប្បាយជាមួយប្តីសម្លាញ់ ។ ស្រាសម្រាប់កំដរពេលបាយគឺស្រាឆ្ងាញ់របស់គ្រូធ្មប់អាហ្វ្រិក ។

និយាយពីព្រះចៅក្រុងចិន តាំងពីថ្ងៃវិមានរបស់បុត្រប្រសាបាត់មិនដឹងហេតុផល ដោយនាំយកទៅនៅជាមួយរាជធីតាបាឡ្រប៊ូឌ្ម

ផង ព្រះអង្គអស់សង្ឃឹមគ្រប់បែបយ៉ាង ព្រះភក្ត្រក្រៀមក្រំគ្មានពេលល្ហែ។ មិនថាថ្ងៃល្អឬយប់ ព្រះអង្គអត់ដែលបានផ្ទុំលក់មួយស្រឡេតឡើយ ។ កាលមុន. មួយថ្ងៃព្រះអង្គយាងទៅបន្ទប់ទំនេរម្តង ពិសេសពេកព្រឹកព្រលឹមស្រាង ដើម្បីទតវិមានដ៏អស្ចារ្យ ដែលបុត្រីព្រះអង្គកំពុងគង់ក្នុងនោះយ៉ាងសុខសាន្តជាមួយស្វាមី ឥឡូវយ៉ាងតិចក៏មួយថ្ងៃដប់ដងដែរដែលព្រះអង្គយាងទៅបន្ទប់ទំនេរដដែលនោះ តែមិនមែនដើម្បីទតវិមានទេ គឺទតវាលទទេ ជាមួយការអស់សង្ឃឹមយ៉ាងធំផេង. ទឹកនេត្រាហូររហាម ។

នាថ្ងៃវិមានអាឡាដាំងត្រូវបានទេពចម្លែកទាសករចង្កៀងទិព្វយកមកដាក់នៅកន្លែងដដែលវិញ គ្រាន់តែភ្លឺស្រាង១ភ្លាម ព្រះរាជាយាងដល់បន្ទប់ទំនេរហើយស្រេច ។ ជាមួយអារម្មណ៍កំពុងនឹកថាលើកនេះមិនខុសមុន១ ពុំឃើញអ្វីក្រៅពីវាលទទេ ស្រាប់តែព្រះអង្គភ្ញាក់ព្រើត ពេលចោលព្រះនេត្រទៅរកទិសទល់មុខវាំង ដោយឃើញមានអ្វីស្កុង១ រាងដូចវិមាន ។ ដំបូងព្រះអង្គស្មានថាព្រលឹមអុរ ពពកហើរទាប តែលុះប្រឹងពិនិត្យម្តងទៀត ក៏ឃើញច្បាស់មិនមែនដុំពពកទេ គឺវិមានអាឡាដាំងទាំងស្រុង ។ ព្រះអង្គស្ទុះចេញក្រៅ បញ្ជាឱ្យគេយកអាជានេយ្យថ្វាយជាបន្ទាន់ ។ ភាពប្រញាប់ប្រញាល់របស់ព្រះអង្គធ្វើឱ្យផ្អើលច្រួលច្របល់ពេញវាំង ។

ចំណែកអាឡាដាំង នាព្រឹកនោះក្រោកស្លៀកពាក់តាំងពីព្រលឹម



ហើយស្រេចព្រោះគិតថា ទោះយ៉ាងណាក៏ព្រះរាជាយាងមកនៅពេលអាចមើលអ្វីឃើញច្បាស់ ។ ដោយសារត្រៀមលក្ខណៈបានល្អ គ្រាន់តែព្រះរាជាយាងមកដល់ភ្លាម នាយមានមុខធ្វើបដិសណ្ឋារកិច្ចយ៉ាងទាន់ពេលវេលា ។

ព្រះរាជាងាកឆ្វេងងាកស្តាំ អត់ឃើញរាជធីតាក៏មានបន្ទូលដោយព្រះសូរសៀងខ្លាំង១ :

- ឯណាបុត្រីយើង? យើងនិយាយរកឯងលុះត្រាបានឃើញនិងឱបថើបបុត្រីយើងសិន ។

អាឡាដាំងប្រណម្យទូលថ្វាយ :

- សូមព្រះបិតាយាងចូលសិន. រាជធីតាកំពុងគង់ក្នុងបន្ទប់របស់ព្រះនាង។ ព្រះនាងមិនបាននឹកស្មានបិតាយាងមកព្រលឹមដូច្នេះ។

ចប់វាចានាយនាំព្រះរាជាយាងឆ្ពោះបន្ទប់រាជធីតាបាគ្រុនប៊ូឌ្លួមពេលរាជធីតាកំពុងចេញពីក្នុង។ ព្រះរាជាបន្លឺបានតែពាក្យ "បុត្រីសំឡាញ់..." រួចខ្សឹកខ្សួលស្ទុះឱបរាជធីតា។ បិតានិងបុត្រអួនណែនអស់មួយសន្ទុះធំទម្រាំបន្លឺបានវិញ ដោយព្រះរាជាមានតម្រាស់សួរមុន

- បុត្រីសំឡាញ់បិតា ប៉ុន្មានថ្ងៃនេះបុត្រមានការតក់ស្លុតនិងទុក្ខសោកខ្លាំងណាស់មែនទេ. ប្រាប់មកមើល៍. ហេតុការណ៍កន្លងមកយ៉ាងម៉េចខ្លះបានជាបុត្រីត្រូវបាត់ខ្លួនជាមួយវិមាន? ប៉ុន្មានថ្ងៃមុនបុត្រីទៅដល់ណា?

រាជធីតាជូតព្រះនេត្របណ្ដើរមានបន្ទូលបណ្ដើរ :

- ក្រាបទូលបិតា. ប៉ុន្មានថ្ងៃនេះនាងខ្ញុំម្ចាស់ត្រូវគេចាប់ពង្រត់យកទៅទ្វីបអាហ្វ្រិកឯណោះ ។ នាងខ្ញុំម្ចាស់តក់ស្លុតណាស់. គឺការតក់ស្លុត ដោយសារឃើញខ្លួនស្រាប់តែនៅលើទឹកដីផ្សេង និងដោយសារអស់សង្ឃឹមគ្រប់បែបយ៉ាង។ ការតក់ស្លុតនោះគ្មាននរណាអាចព័ណ៌នាបាន ។ ទើបតែព្រឹកមិញទេ ដែលនាងខ្ញុំម្ចាស់ស្បើយទុក្ខ ព្រោះពេលនោះបានជួបបងអាឡាដាំងវិញ ។ បន្ទាប់ពីបែកគ្នាដោយចៃដន្យ ព្រឹកម្សិលមិញគាត់ទៅដល់ទ្វីបអាហ្វ្រិក ហើយក៏បានជួបនាងខ្ញុំម្ចាស់ក្នុងស្ថានភាពកំពុងតឹងតែងមែនទែន ។ ដោយសារគាត់ ទើបនាងខ្ញុំម្ចាស់អាចត្រឡប់មកដល់នគរពីយប់មិញ និងបានឃើញព្រះបិតាព្រឹកនេះ...

រំលឹកដល់គ្រោះថ្នាក់នេះ រាជធីតាបាទ្រូប៊ូឌូមិនទាន់បាត់តក់ស្លុតនៅឡើយ។ ព្រះនាងរៀបរាប់ទាំងរន្ធត់ញាប់ញ័រ. ម្ល៉ោះហើយត្រូវអាក់ខានអស់បន្តិចទើបមានបន្ទូលទៀតបាន :

- តាមពិត. មូលហេតុនាំឱ្យមានគ្រោះថ្នាក់គឺបណ្ដាលមកពីបុត្រីទាំងស្រុង គ្មានពាក់ព័ន្ធជាមួយបងអាឡាដាំងទេ ព្រោះពេលនោះគាត់ទៅបរបាញ់ អត់បានដឹងរឿងរ៉ាវអ្វីទាំងអស់ ។ គាត់ទើបតែចេញទៅប៉ុន្មានថ្ងៃ នាងខ្ញុំម្ចាស់ត្រូវជនទុច្ចរិតបោកប្រាស់បាន ហើយក៏ត្រូវវាចាប់ពង្រត់ទាំងវិមាននាំទៅទ្វីបអាហ្វ្រិក ។ សូមព្រះបិតាកុំបន្ទោសគាត់ ។



ដើម្បីឱ្យព្រះរាជាយល់សម្ដីនេះ បន្ទាប់ពិឆ្លើយត្រួស១ប៉ុណ្ណោះ រាជធីតាក៏រ៉ាយរ៉ាប់លម្អិតតាំងពីរបៀបបន្លំខ្លួនរបស់ជនឃោរឃៅយ៉ាងម៉េចខ្លះ. ក្រោយមកត្រូវជនឃោរឃៅតាមលួងលោមយ៉ាងម៉េចខ្លះ និងទីបំផុតបានជួបអាឡាដាំង រួមគ្នាអនុវត្តឧបាយកលបំពុលសម្លាប់ជនឃោរឃៅវិញ ។ ចុងក្រោយបង្អស់ ព្រះនាងសរុបយ៉ាងខ្លី :

- បន្ដពីនេះ នាងខ្ញុំម្ចាស់សូមប្រគល់នាទីឱ្យបុត្រប្រសាបិតារៀបរាប់ម្ដង ។ ·

ព្រះរាជាបែរទៅខាងអាឡាដាំង :

- ក្រោយពេលជនកំណាចត្រូវបំពុលស្លាប់ តើមានការប្រែ-ប្រួលយ៉ាងម៉េចទៀត?

អាឡាដាំងគ្មានពាក្យអ្វីច្រើនសម្រាប់បូរបាច់យូរ ព្រោះដំណើររឿងអកុសលនោះឈានដល់ទីបញ្ចប់ទៅហើយ. ដូច្នេះនាយគ្រាន់តែនិយាយបន្ដយ៉ាងខ្លី :

- ពេលបានទទួលដំណឹងចុងក្រោយ ទូលបង្គំរត់ឡើងសាលទទួលភ្ញៀវ ឃើញជនកំណាចស្លាប់មែន ។ ភ្លាមនោះទូលបង្គំប្រាប់រាជធីតាឱ្យយាងចុះក្រោម និងហៅអ្នកឯទៀតទាំងអស់ចុះតាម រួចហើយទូលបង្គំអន្ទងទេពចម្លែកតាមរបៀបដុះចង្កៀងទិព្វ។ លុះទេពចម្លែកបង្ហាញខ្លួន ទូលបង្គំក៏ប្រើឱ្យយកវិមានត្រឡប់មកវិញជាបន្ទាន់។ តែដោយហេតុមកដល់យប់ជ្រៅគួរសមដែរហើយ ទើបទូលបង្គំមិន

ទាន់បានទៅថ្វាយបង្គំព្រះបិតានិងព្រះមាតា ។ ទូលបង្គំសូមទូលថ្វាយបញ្ជាក់ថា សពរបស់ជនឃោរឃៅនៅទុកចោលក្នុងសាលទទួលភ្ញៀវនៅឡើយសម្រាប់ជាភស្តុតាងស្រាយបំភ្លឺពីហេតុកន្លងមក ។

ឮដូច្នេះព្រះរាជាចង់ស្គាល់មុខគ្រូធ្មប់អាហ្វ្រិកក៏ទៅជាមួយអាឡាដាំង :

- នាំយើងទៅមើលមុខវាផងមើល៍ !

ព្រះអង្គប្រាប់បុត្រប្រសាឱ្យនាំផ្លូវ តែតាមពិតមានព្រះតម្រាស់រួចព្រះអង្គយាងឡើងដោយខ្លួនឯង ចំណែកអាឡាដាំងដើរតាមក្រោយ ។ ពេលឃើញច្បាស់ជនកំណាចមុខមាត់ស្លេកស្លាំងដោយត្រូវថ្នាំពុល កំពុងដេកស្លាប់លើកម្រាល ព្រះអង្គឱបថើបអាឡាដាំង ព្រមទាំងមានបន្ទូលលួងលោម :

- កន្លងមកបិតាយល់ច្រឡំ. ប្រព្រឹត្តមិនគប្បីចំពោះបុត្រ ។ សំណាងដែរដែលកាលណោះប្រជានុរាស្ត្របះបោរទម្លាយវាំងបាន. កុំអីបិតាត្រូវមានវិប្បដិសារីអស់មួយជីវិត ។ ឥឡូវបិតាយល់ការពិតហើយ. សូមបុត្រកុំប្រកែប្រកាន់ ។

- ក្រាបទូលបិតា. (អាឡាដាំង) បើទូលបង្គំអាក់អន់ចិត្តក្នុងរឿងនេះ គឺទូលបង្គំជាអ្នកខុស ព្រោះមូលហេតុពីគ្រូធ្មប់អាហ្វ្រិកឯណោះទេ ។ ជននោះអាក្រក់ឃោរឃៅរកលេខដាក់គ្មាន ចាំថ្ងៃណាបិតាទំនេរទូលបង្គំនិងរៀបរាប់ប្រវត្តិរបស់វាថ្វាយជាទីសណ្ដាប់ ។ ទូល



បង្គំធ្លាប់រងគ្រោះថ្នាក់ដោយសារវាតាំងពីនៅតូច ពុំមែនទើបតែលើកនេះទេ ។ ទូលបង្គំជឿថាប្រវត្តិរបស់វា គឺជាសាច់រឿងចម្លែកមួយ ។

ព្រះរាជាងក់ព្រះកេស :

- យើងនឹងលៃលកចំណាយពេលមួយព្រឹក ឬមួយល្ងាចស្លាប់រឿងនេះ ។ ឥឡូវបុត្រយកសាកសពដ៏កម្រក់របស់វាគ្រវាត់ចោលទៅ ។

អាឡាដាំងទទួលបញ្ជា ប្រាប់ទាសករឱ្យលីសពគ្រូធ្មប់អាហ្វ្រិកទៅចោលក្នុងព្រៃឱ្យសត្វស៊ីជាអាហារ ។ ចំណែកព្រះរាជាវិលត្រឡប់មកបរមរាជវាំងវិញ បញ្ជាឱ្យទូងស្គរបន្ទរតាំងប្រកាសដំណឹងមហារីករាយរបស់ព្រះអង្គ. ហើយទ្រង់អនុញ្ញាតគ្រប់មន្ត្រីនិងប្រជានុរាស្ត្រទូទាំងនគររៀបចំកម្មវិធីកំសាន្តសប្បាយដប់ថ្ងៃដប់យប់ ដើម្បីអបអរសាទរចំពោះដំណើរនិវត្តដោយសុវត្ថិភាពរបស់បុត្រីនិងបុត្រប្រសាព្រះអង្គ ។

នេះជាលើកទីពីរហើយ ដែលអាឡាដាំងបានឆ្លងផុតគ្រោះ-ថ្នាក់ធ្ងន់ធ្ងរវិះអស់ជីវិត ។ ទាំងលើកទីមួយក៏ដូចជាលើកទីពីរ ការឆ្លងផុតរបស់នាយមានភាពអស្ចារ្យក្រៃលែង ។ ប៉ុន្តែទោះដូច្នេះក្ដី ថ្វីបើគ្រូធ្មប់អាហ្វ្រិកលែងមានជីវិតនៅលើផែនដី ក៏នាយមិនទាន់ចប់ទុក្ខនៅឡើយ. ប៉ុន្មានខែក្រោយមកជួបគ្រោះថ្នាក់ជាលើកទីបីវិះអស់លើកទីបី គឺមកពីប្អូនប្រុសគ្រូធ្មប់អាហ្វ្រិក ។ តាមពិតគ្រូធ្មប់អាហ្វ្រិក

មានប្អូនប្រុសម្នាក់ទៀត. គេនោះមិនត្រឹមតែចេះវេទមន្តខ្លាំងពូកែប៉ុណ្ណោះទេ ថែមទាំងជាមនុស្សពិសពុលប្រកបដោយល្បិចកលខ្ពស់ជាងបងគេទៀតផង ។ ថ្វីបើជាបងប្អូនបង្កើត តែជនកំណាចទាំងពីររស់នៅបែកគ្នា. ដើរលុកលុយតាមបែបផ្សេងពីគ្នា។ យូរៗម្តង ជួនពីរឆ្នាំ ឬបីឆ្នាំ រៀបវិធីប្រមើលមើលគ្នាទៅវិញទៅមក តើបងឬប្អូនកំពុងនៅឯណា. ធ្វើអី. ជីវិតឈានដល់សភាពបែបណា. សុខសប្បាយឬមានទុក្ខ ។

បន្ទាប់ពីគ្រូធ្មប់អាហ្វ្រិកស្លាប់យ៉ាងថោកទាប ប៉ុន្មានខែក្រោយស្រាប់តែប្អូនប្រុសគាត់នឹកភ្នកបងរបស់ខ្លួន យូរណាស់ហើយពុំដឹងបងទៅដល់ណា និងកំពុងធ្វើអី ។ ជនឃោរឃៅក៏យកសម្ភារៈចេញរៀបពិធីប្រមើលមើលតាមរបៀបច្រើនជំហាន ។ ចាប់ផ្តើមជំហានដំបូងវាភ្ញាក់ហើបខ្លួន ដោយដឹងបងប្រុសស្លាប់តាំងពីប៉ុន្មានខែមុនម្ល៉េះ. ជំហានទីពីរ វាដឹងមរណភាពនោះបណ្តាលមកពីត្រូវថ្នាំបំពុល មិនមែនដោយឈឺថ្កាត់ឡើយ។ ជំហានទីបីដឹងមុខអ្នកសម្លាប់គឺប្តីប្រពន្ធអាឡាដាំង ដែលសព្វថ្ងៃកំពុងរស់នៅយ៉ាងរុងរឿងនៅប្រទេសចិន។ ជំហានទីបួនពិនិត្យភូមិសាស្ត្រទីកន្លែងដែលប្តីប្រពន្ធអាឡាដាំងកំពុងរស់នៅ។ ជំហានចុងក្រោយ ស្រាវជ្រាវប្រវត្តិប្តីប្រពន្ធអាឡាដាំង វារកឃើញថាអាឡាដាំង ជាកូនទោលរបស់គ្រួសារមួយក្រីក្របំផុត តែដោយសារយកបានចង្កៀងទិព្វដោយចៃដន្យ និងយល់របៀបប្រើប្រាស់ដោយ



ចៃដន្យ ទើបអាចឈានឡើងឥតឈប់ឈរ ក្លាយជាអ្នកមានធនធានដាច់គេលើផែនដី ហើយចុងក្រោយក្លាយជាកូនប្រសាស្តេច ។

បន្ទាប់ពីប្រមើលមើលសព្វគ្រប់ ជនឃោរឃៅសង្កៀតធ្មេញនិយាយម្នាក់ឯង :

- យើងត្រូវតែសងសឹកឱ្យបងរបស់យើង ។ ក្នុងនាមកូនប្រុសទ្រូងប្រាំហត្ថធ្លាប់លុកលុយគ្រប់ច្រកល្ហកលើផែនដី ដាច់ខាតយើងមិនអនុញ្ញាតឱ្យជនដែលសម្លាប់បងយើងអាចរស់ក្នុងសុភមង្គលទេ ។ វាត្រូវតែស្លាប់. ចំណែកចង្កៀងទិព្វនោះត្រូវតែបានជារបស់យើង ដើម្បីយើងត្រួតត្រាផែនដីនេះទាំងមូល ។

ជាមួយការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ស្អែកឡើងជនឃោរឃៅយកសេះមួយក្បាលធុនពូកែ ជិះធ្វើដំណើរសំដៅនគរក្រុងចិន។ បន្ទាប់ពីឆ្លងកាត់រាល់ការលំបាក បន្ទាប់ពីពុះពាររាប់ខែ ទីបំផុតវាបានមកដល់គោលដៅយ៉ាងស្ងៀមស្ងាត់ ឥតមាននរណាដឹងវាជាមនុស្សប្រភេទណា មកពីខាងណា មានបំណងដូចម្តេចឡើយ ។ ដោយហេតុក្នុងរាជធានីមានជនបរទេសចេញចូលលក់ដូរច្រើន អ្នកផងក៏ស្មានថាវាជាឈ្មួញបរទេសដូចឈ្មួញឯទៀតដែរ ។

សម្រាកមួយយប់ ស្អែកឡើងជនកំណាចចាប់ផ្តើមចេញដើរតាមផ្លូវនានា. មិនមែនដើម្បីកំសាន្តទិដ្ឋភាពប្លែកៗទេ គឺដើម្បីស្តាប់សភាពការណ៍ក្នុងគោលដៅរិះរកមធ្យោបាយសងសឹកនិងដណ្តើមយក

ចង្កៀងទិព្វ ។ វាបន្លំខ្លួនជ្រៀតចូលកន្លែងមួយមនុស្សអ៊ូអរជាងគេ សំបូរហាងស៊ីផឹកជាងគេ, នៅទីនោះអ្នកខ្លះលេងល្បែងស៊ីសង អ្នកខ្លះនិយាយគ្នារឿងស្នេហា រឿងជួញដូរ ។ ប៉ុន្តែមានមួយចំនួនធំកំពុងនិយាយរឿងដូនជីឈ្មោះហ្វាទីម គឺជាដូនជីម្នាក់បានទទួលការសរសើរពីគុណធមិនិងមេត្តាធមិគួរឱ្យគោរព ជាទីពឹងដ៏កក់ក្តៅរបស់បរិស័ទ។ គាត់ទៅដល់ណាត្រជាក់ត្រជុំដល់នោះ ។ ស្តាប់បានត្រួស១ប៉ុណ្ណេះវានឹកក្នុងចិត្ត : “ដូនជីហ្វាទីមអីគេនោះ ប្រហែលអាចធ្វើចំណុចចាប់ផ្តើមរបស់ផែនការយើងបាន ។ បើប្តីប្រពន្ធអាឡាដាំងជ្រះថ្លាចំពោះដូនជីហ្វាទីមដូចអ្នកឯទៀតដែរ យើងពិតជាមានលទ្ធភាពជ្រៀតចូលក្នុងវិមានរបស់វា ដើម្បីធ្វើសកម្មភាពបានតាមចិត្ត, ហើយវាក៏គ្មានសង្ស័យអ្វីសោះ” ។

គិតឃើញដូច្នេះ វាសរសៀរចូលជិតបុរសម្នាក់បានមាត់បានកជាងគេ សួរពីប្រវត្តិដូនជីហ្វាទីម តើគាត់ជានរណា មានគុណធមិនិងសមត្ថភាពដូចម្តេចខ្លះ ។ បុរសនោះនឹកឆ្ងល់បើកភ្នែកធំ១សួរវិញ :

- ក្នុងរាជធានីនេះទាំងមូល អ្នកណាក៏ដឹង ក៏គោរពដូនជីហ្វាទីម ចន្លោះតែលោកពូម្នាក់ម៉េចអត់ដឹងអ៊ីចឹង?

ជនឃោរឃៅធ្វើជាសើចយកចិត្តយកថ្លើម ឆ្លើយតប :

- ខ្ញុំជាអ្នកជំនួញស្រុកឆ្ងាយ ទើបតែមករាជធានីនេះលើកដំបូង, សូមលោកប្អូនកុំប្រកែប្រកាន់ ។



បុរសនោះជឿស្លុង ងក់ក្បាលផ្ងក់១ :

- អូ, លោកពូជនបរទេសឬ? មិនអីទេ, ចាំខ្ញុំជម្រាប : ដូនជីហ្វាទីមជាអ្នកបួសធ្វើទុក្ករកិរិយាម្នាក់ឯងក្នុងអាស្រមមួយតូច ។ គាត់សម្រេចមគ្គផល អាចជួយសង្គ្រោះសត្វលោកបានគ្រប់គ្រា។ ក្រៅពីថ្ងៃច័ន្ទ និងថ្ងៃសុក្ររៀងរាល់សប្តាហ៍ដែលត្រូវសម្ងំភាវនាក្នុងអាស្រមគាត់តែងដើរចច្រប់គ្រប់ទិសទីដើម្បីប្រសិទ្ធពរជ័យដល់បរិស័ទ។ អ្នកឈឺចុកចាប់ក្នុងខ្លួនយ៉ាងណាខ្លះ ឱ្យតែជួបគាត់និងបានគាត់ស្ទាបថ្ងាសម្តងតែងជាសះស្បើយមានកម្លាំងកំហែងឡើងវិញ ។ ក្នុងរាជធានីនេះគាត់ដើរដល់ណា អ្នកស្រុកសំពះវន្ទាដល់នោះ។ សរុបមកដូនជីហ្វាទីមជាអ្នកបួសមួយរូបដែលលះបង់រាល់ផលប្រយោជន៍របស់ខ្លួន ដើម្បីផលប្រយោជន៍បរិស័ទគ្រប់រូប ជាអ្នកបួសប្រកបដោយគុណធមិខ្ពង់ខ្ពស់គួរឱ្យគោរព ។ បើលោកពូបាននៅក្នុងក្រុមនេះយូរបន្តិច, លោកពូនឹងឃើញថាខ្ញុំនិយាយត្រូវមែន ។

ប្អូនប្រុស គ្រួធ្មប់អាហ្វ្រិកអត់ចង់ដឹងអ្វីថែមទៀតក្នុងរឿងនេះទេ វាគ្រាន់តែសួរពីអាស្រមរបស់ដូនជីតាំងនៅកន្លែងណា រួចនឹកក្នុងចិត្ត: “យើងត្រូវបន្លំខ្លួនជាដូនជីហ្វាទីម.... ហាស់ ! ហា ! មធ្យោបាយដ៏ល្អបានមកដោយចៃដន្យ ។ កុំអីយើងប្រហែលចំណាយពេលយូរទើបអាចជ្រៀតចូលវិមានអាឡាដាំងបាន ហើយក៏មិនច្បាស់ជាទទួលជោគជ័យឬបរាជ័យផងទេ” ។

ដោយហេតុពេលនេះចំលើថ្ងៃដូនជីហ្វាទីមសម្ងំភាវនាធម៌. ជនឃោរឃៅត្រូវទ្រាំចាំដល់ថ្ងៃស្អែកទើបមានលទ្ធភាពអនុវត្តផែនការពិសពុល ។ វាលបមើលសកម្មភាពដូនជីគ្រប់ជំហាន ដើរតាមពីក្រោយគាត់រហូត. ទិបំផុតតាមដល់អាស្រមទៀត ។ នៅទីនោះ បន្ទាប់ពីពិនិត្យភូមិសាស្ត្រជុំវិញអាស្រមហើយ វាត្រឡប់មកផ្ទះសំណាក់ទាំងញញឹមសង្ឃឹមមួយរយភាគរយ ។

យប់ជ្រៅបន្តិច ជនឃោរឃៅធ្វើដំណើរសំដៅអាស្រមដូនជីហ្វាទីម ។ ទ្វាររបងគ្រាន់តែដាក់គន្លឹះឈើធម្មតា វាលូកដៃដោះយ៉ាងងាយ. រួចដើរតម្រង់ចូលក្នុង ។ ក្រោមពន្លឺព្រះច័ន្ទ វាឃើញដូនជីក្តៅស្អុះចេញសម្រាន្តកណ្តាលវាលលើគ្រែកញ្ចាស់មួយ. គាត់សម្រាន្តលក់ស្រួលអត់ដឹងមានគ្រោះថ្នាក់មកដល់ឡើយ ។ មិនបង្អង់យូរ វាហូតកាំបិតស្នៀតសស្ងាចចេញពីចង្កេះ រួចលូកដៃម្ខាងទះគ្រែដាស់ដូនជី ។

ភ្ញាក់នឹងស្នូរផាច់ៗ ដូនជីហ្វាទីមស្ទុះក្រោកមីងមាំង. ទើបតែក្រោកឡើងគាត់ត្រូវញាក់ទទ្រើត ដោយឃើញមនុស្សប្រុសម្នាក់ភ្ជង់កាំបិតប្រុងសម្លាប់គាត់ ។ ពុំដឹងរឿងអី គាត់សួរទាំងញ័រមាត់ប៉ប៉ុប :

- លោក.... លោកជានរណា? ប្រុងធ្វើអីហ្នឹង?

ជនកំណាចតម្រង់ចុងកាំបិតចំទ្រូងដូនជី. បន្លឺយ៉ាងកាច :

- យាយឯងហ៊ានតែស្រែកមួយម៉ាត់ ឬបង្កើតស្នូរអ្វីឮដល់ខាងក្រៅ យើងសម្លាប់ចោលភ្លាម ។ ក្រោកឈរឱ្យស្រួល ចាំធ្វើតាមបញ្ជាយើង ប្រសិនបើចង់រស់ ។



ដូនជីហ្វាទីមឈរត្រង់ខ្លួន លែងហ៊ានសួរនាំអ្វីទាំងអស់ ។ ឃើញដូច្នេះជនឃោរឃៅសើចស្ងួតនិយាយបន្ត :

- មិនបាច់ខ្លាចទេ. យើងត្រូវការតែអាវរបស់យាយឯងប៉ុណ្ណោះ តោងដោះអាវនោះមកឱ្យយើង ហើយយកអាវរបស់យើងពាក់ចូល ។ ធ្វើភ្លាមទៅ បើចង់សុខ ។

ដូនជីហ្វាទីមឃើញការតម្រូវនេះមិនធ្ងន់ធ្ងរប៉ុន្មាន ក៏ធ្វើតាមវាដោយដោះអាវរបស់ខ្លួនហុចឱ្យវា រួចទទួលអាវរបស់វាយកមកពាក់ជំនួស ។

ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកពាក់អាវដូនជីរួចវាបញ្ជាទៀត :

- ការងារយាយឯងមិនទាន់អស់ទេ. យាយឯងពិតជាចេះសិល្បៈក្លែងខ្លួន ដូច្នេះតោងរៀបចំកាឡៃមុខយើងឱ្យដូចមុខយាយឯង ហើយអាចរក្សាពណ៌សម្បុរបានយូរថ្ងៃផង ។

មកដល់ពេលនេះ ទើបដូនជីហ្វាទីមសម្គាល់ឃើញមិនស្រួលមែនទែន. អាចបន្តិចទៀតត្រូវវាសម្លាប់ចោលបន្ទាប់ពិរៀបចំមុខវាដូចមុខគាត់ ព្រោះវាហាក់ដូចជាត្រៀមបន្លំរូបគាត់ដើម្បីអនុវត្តផែនការអ្វីមួយ ហើយផែនការនោះប្រហែលជាអាក្រក់ផង ។ ថ្វីបើសន្និដ្ឋានដូច្នេះ តែគាត់ក៏ពុំដឹងដោះស្រាយរបៀបណាឱ្យរួចខ្លួនបាន. គិតតែផ្ញើវាសនាតាមយកថាកម្ម ចាំដល់ពេលនោះសឹមគិតទៀត ។ ជនកំណាចដឹងដូនជីតក់ស្លុតខ្លាំង ព្រោះគាត់យល់បំណងរបស់ វាក៏និយាយអះអាងឱ្យគាត់នឹងនចិត្ត :

- កុំខ្លាចអី. យើងស្បថចំពោះមុខព្រះជាម្ចាស់ថា យើងមិនសម្លាប់យាយឯងទេ យ៉ាងច្រើនគ្រាន់តែបង្ខាំងលោកយាយឯងមួយរយៈក្នុងពេលយើងធ្វើសកម្មភាពតែប៉ុណ្ណោះ ។

ដូនជីហ្វាទីមអត់មានផ្លូវដោះខ្លួន ក៏បង្ខំចិត្តធ្វើតាមបញ្ជាវា ។ គាត់នាំចូលក្នុងអាស្រម. យកកៅអីដាក់ឱ្យអង្គុយ ហើយយកក្រឡទឹកអ្វីម្យ៉ាងដាក់ក្បែរខ្លួនវា បន្ទាប់មកយកជក់មួយជ្រលក់ចូលទឹកនោះប៉ាតឡើងមុខវា ។ គាត់ប៉ាតច្រើនសា. កន្លែងខ្លះថែមទាល់តែក្រាស់. កន្លែងខ្លះស្តើងល្មម. ធ្វើបណ្តើរនិយាយបណ្តើរ :

ក្នុងរវាងកន្លះម៉ោងទៀត មុខលោកក្លាយជាមុខខ្ញុំមួយរយភាគរយ ។

ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកសួរបញ្ជាក់ :

- ចុះពណ៌សម្បុរ?

- អាចរក្សាពណ៌បានរាប់ខែ. មិនមែនត្រឹមបួនដប់ថ្ងៃទេ ។

លុះធ្វើកិច្ចការនេះរួច ដូនជីដោះកន្សែងពីក្បាលខ្លួនឯង ពាក់គ្របឡើងក្បាលជនឃោរឃៅ ហើយយកកញ្ចក់មួយហុចឱ្យវា :

- លោកពិនិត្យមើល តើដូចឬមិនដូច ?

ជនកំណាចផ្ទៀងផ្ទងឆ្លុះកញ្ចក់ ឃើញដូចមួយរយភាគរយអត់ខុសចំណុចណាមួយសោះ. វាពេញចិត្តស្ទួកនឹកថា តែប៉ុណ្ណេះដើរដល់ណា ក៏គេស្មានថាដូនជីហ្វាទីមដែរ ។ ពិនិត្យសព្វគ្រប់រួចវាងក់ក្បាលៈ



- ល្អ. យាយឯងមានស្នាដៃល្អមែន ។

ចប់វាចា ស្រាប់តែវាលែងកាំបិតស្នៀតពីដៃ ហើយស្រវាច្បាមបំពង់កដូនជីហ្វាទីមជាប់ ។ វាពុំបានរក្សាពាក្យសន្យាទេ. វាត្រូវតែសម្លាប់ដូនជីចោលទើបនឹងនចិត្ត ។ ដំបូងវាប្រុងសម្លាប់ដោយចាក់នឹងកាំបិតស្នៀត តែគិតចុះគិតឡើង ខ្លាចត្រូវសង្ស័យ ព្រោះតិចឬច្រើនទៀងពីមានបន្សល់ស្លាកស្នាមឈាមក្នុងអាស្រម. ដូច្នេះហើយទើបវាច្របាច់កគាត់វិញ ។ វារឹតបាតដៃទាំងពីរទាល់តែដូនជីហ្វាទីមដាច់ខ្យល់ដួលគ្រឹបលែងរើបម្រះ ទើបបន្ធូរសន្សឹម១. ចុងក្រោយបង្អស់វាលើកសពគាត់យកទៅទម្លាក់ចុះអណ្តូងទឹកមួយដែលនៅមិនឆ្ងាយប៉ុន្មានពីអាស្រម ។

អាសូរដូនជីហ្វាទីមដែលខំបួសសន្សំកុសល សាងតែអំពើល្អសង្គ្រោះសត្វលោកអត់រើសមុខ ទីបំផុតត្រូវអស់សង្ខារដោយសារជនព្រៃផ្សៃតិរច្ឆានទៅវិញ ។

បន្ទាប់ពីប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវ ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកដេកក្នុងអាស្រមមួយយប់. ភ្លឺឡើង ពេលព្រះអាទិត្យរះច្បាស់បន្តិចក៏ចេញដើរសំដៅទៅខាងតំបន់វិមានអាឡាដាំង ។ វាត្រាប់ដំណើររមទម្យស្រគត់ស្រគុំរបស់ដូនជីហ្វាទីម ដែលវាបានសង្កេតនឹងបានចងចាំតាំងពីថ្ងៃម្សិលមិញ ។

បរិស័ទប្រុសស្រីក្រឡេកឃើញជនឃោរឃៅស្មានថាដូនជីហ្វា-

ទីមជាទីគោរពសក្ការៈ ក៏រត់ឈូសរមកបង្គំវន្ទាជាមួយសំនូមពរផ្សេងៗ ខ្លះសូមដូនជីប្រទានពរ ខ្លះសុំថើបដៃ. អ្នកណាឈឺក្បាលវិលមុខម៉្មីម្នា ឱនក្បាលសុំឱ្យដូនជីស្ទាបអង្អែលបំបាត់រោគា។ ជនកំណាចត្រាប់កាយវិការដូនជីបានទាំងអស់ អ្នកណាសុំឱ្យតែប្រទានពរ វាធ្វើមាត់អេចអូចដូចសូត្រធម៌ឱ្យពរជ័យ. អ្នកណាសុំថើបដៃហុចដៃឱ្យថើប. អ្នកណាអោនក្បាលមក វាលូកដៃត្រដុសអង្អែលស្រាលៗ គ្មានបរិស័ទណាម្នាក់ចាប់ភ្លឹកសង្ស័យចំណុចអ្វីមួយឡើយ ។ រួចពីមួយកន្លែង វាបន្តដំណើរទៅមុខទៀត រហូតដល់ចុងក្រោយបង្អស់វាក៏បានទៅដល់ទីធ្លាខាងមុខវិមានអាឡាដាំង ។ នៅទីនោះបរិស័ទតាមមកកាន់តែច្រើនឡើងៗ ដល់ថ្នាក់ម្នាក់ៗប្រជ្រៀតគ្នាបែកញើសរហាមទើបអាចចូលជិតដូនជីក្លែងក្លាយបាន។ ការប្រជ្រៀតឥតឈប់ឈរពេលខ្លះ ឈានដល់ប៉ះទង្គិចទាស់ទែងគ្នាក៏មាន ។

ពេលនោះ រាជធីតាបាគ្រ្ទប៊ូឌូ កំពុងគង់ក្រសាលក្នុងសាលទទួលភ្ញៀវ ដោយមានភីល្លៀងបួនប្រាំនាក់អង្គុយគាល់ និងប្រធានកងទាសកររកម្រៀវឈរការពារនៅម្ខាង ។ ព្រះនាងឃើញមនុស្សអ៊ូអរប្លែកធម្មតា ថែមទាំងមានសំឡេងជជែកគ្នាទ្រហឹងអឹងអាប់ផង ក៏សួរតើមានរឿងអី តែពួកភីល្លៀងក៏ដូចប្រធានទាសកររកម្រៀវអត់បានដឹងដូចព្រះនាងដែរ ។ កាន់តែឆ្ងល់ឡើង ព្រះនាងបញ្ជាភីល្លៀងម្នាក់ទៅមើល ក្រែងលោមានហេតុភេទមិនល្អណាមួយ ។ ភីល្លៀងនោះរត់ចុះក្រោមអើតពិនិត្យមួយសន្ទុះក៏រត់ឡើងវិញទូលថា :



- ក្រាបទូល. មិនមែនហេតុភេទអាក្រក់អ្វីទេ គឺបរិស័ទប្រ-ជ្រៀតគ្នាខ្លាំងពេក អ្នកខ្លះទាស់ពាក្យទាស់សម្តីគ្នា ។

រាជធីតាបាគ្រ្ទប៊ូឌូធ្លាប់ឮឈ្មោះដូនជីហ្វាទីមយូរហើយ តែមិនដែលឃើញមុខ។ ឮដូច្នេះចង់ស្គាល់ផង ចង់ធ្វើគារវកិច្ចសុំពរជ័យពីដូនជីផង ព្រះនាងក៏ប្រាប់ប្រធានកងទាសកររកម្រៀវ :

- ខ្ញុំចង់ជួបដូនជីផ្ទាល់, សូមលោកដោះស្រាយតាមសម្រួល ។

ប្រធានកងទាសកររកម្រៀវប្រញាប់ប្រញាល់ហៅទាសកររកម្រៀវបួននាក់ បញ្ជាឱ្យចុះទៅអញ្ជើញដូនជីហ្វាទីម, ប្រាប់ថារាជធីតាសុំអញ្ជើញគាត់ចូលសម្រាកក្នុងវិមាន ។

ពេលក្រុមទាសកររកម្រៀវដើរសំដៅជនកំណាចដែលក្លែងខ្លួនជាដូនជីហ្វាទីម ពួកបរិស័ទថយចេញអស់ឈប់ប្រជ្រៀតគ្នាទៀត ព្រោះមិនដឹងមនុស្សរបស់ស្តេចមកមានការអី ។ ចំណែកប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកបានស្រឡះខ្លួន ទទួលឃើញពួកទាសកររកម្រៀវក៏អរភើតនឹកថាផែនការរបស់វាមានសង្ឃឹមកាន់តែច្រើន ។

ទាសករម្នាក់ដែលនាំមុខគេក្នុងចំណោមបួននាក់ ដោយស្មានជនកំណាចជាដូនជីហ្វាទីមមែន ពេលទៅដល់ម្ចី ម្នាផ្គុំហត្ថប្រណម្យតាមរបៀបគោរពអ្នកបួស រួចនិយាយ :

- ជម្រាបលោកយាយជាទីសក្ការៈ, ព្រះរាជធីតាបាគ្រ្ទប៊ូឌូរបស់យើងខ្ញុំមានក្តីជ្រះថ្លាខ្លាំងចំពោះលោកយាយ, ព្រះនាងសូមអញ្ជើញលោកយាយចូលវិមាន ។

ជនឃោរឃៅបើកភ្នែកធំៗ ធ្វើជាភ្ញាក់ផ្អើល :

- អូ, ព្រះរាជធីតាយកចិត្តទុកដាក់នឹងខ្ញុំមែនឬ? សាធុ ! ព្រះនាងផ្តល់កិត្តិយសខ្ពង់ខ្ពស់ណាស់ ។ ខ្ញុំត្រូវតែទៅដើម្បីប្រទានពរជ័យថ្វាយព្រះនាង ។

ថាហើយវារៀបដំណើរសង្រួមដើរយ៉ាងស្រគត់ស្រគុំតាមក្រោយពួកទាសករកម្រៀវ តែដើរបណ្តើរវានឹកក្នុងចិត្តបណ្តើរៈ “នេះជាអំណោយផលហួសការស្មានមែន” ។

ពេលឡើងដល់សាលទទួលភ្ញៀវមានបង្អួចម្តុំបួន ជនកំណាចក្រឡេកឃើញរាជធីតាបាឱ្រប៊ូឱ្យភ្លាម ក៏ធ្វើមាត់អេចអូចញាប់ស្មេញដូចប្រឹងសូត្រធម៌ប្រទានពរ, អេចអូចមួយសន្ទុះចាប់ផ្តើមបន្លឺសុទ្ធតែពាក្យបួងសួងសុំឱ្យរាជធីតាមានព្រះជន្មាយុយឺនយូរ មានព្រះកាយពលមាំមួនក្នុងសម្ពស្សផ្ទូរផង់ជានិច្ចនិរន្តរ៍, រួចហើយប្រើប្រាស់ហោរាដ៏ប៉ិនប្រសប់របស់មនុស្សខូចនិយាយប៉ប៉ោចៗ អួតអាងពីគុណធម៌ ពីការខិតខំធ្វើទុក្ករកិរិយាដើម្បីបានសម្រេចមគ្គផល ពីការអាណិតអាសូរសត្វលោក ពិសេសជនអភ័ព្វទាំងឡាយដែលកើតមកខ្សត់ទ្រព្យធនជួបការលំបាកតោកយ៉ាកក្នុងជីវិត ។ ដោយសារវាមានល្បិចនិយាយខ្ពស់ រាជធីតាកាន់តែជឿវាជាអ្នកបួសមួយរូបគួរឱ្យគោរពជ្រះថ្លាក្រៃលែង ហើយមានបន្ទូលសរសើរការលះបង់កន្លងមក ដែលដូនជីតែងដើរសង្គ្រោះបរិស័ទឥតគិតដល់ការនឿយហត់ផ្ទាល់ខ្លួន ។ ចុងក្រោយ



បង្អស់ ព្រះនាងអញ្ជើញវាឱ្យអង្គុយក្បែរ ដោយប្រើពាក្យ “អ្នកម៉ែៗ” រួចមានបន្ទូលស្នើ :

- កូនសូមអ្នកម៉ែអនុញ្ញាតឱ្យនិយាយរឿងមួយទៀត សង្ឃឹមថាអ្នកម៉ែមិនបដិសេធទេ ។

ជនកំណាចបង្ហាញឫពាស្រគត់ស្រគុំតប :

- សូមរាជធីតាមានបន្ទូលតាមសព្វហឫទ័យ, យាយអាចត្រង់ត្រាប់ស្តាប់បានទាំងអស់ ។

ទាំងសម្តីទាំងកាយវិការ វាធ្វើឱ្យរាជធីតាកាន់តែជ្រះថ្លាខ្លាំងឡើង ក៏មានបន្ទូលត្រង់ៗ :

- កូនស្នើសុំអ្នកម៉ែនៅទីនេះជាមួយកូនរហូត បើមិនរហូតក៏មួយរយៈណានោះដែរ ដើម្បីអ្នកម៉ែបានប្រទានពរកូនព្រឹកល្ងាច និងដើម្បីឱ្យកូនបានត្រង់ត្រាប់រៀនសូត្រគំរូល្អប្រពៃរបស់អ្នកម៉ែ ។

- មិនបានទេរាជធីតា, យាយជាអ្នកបួសចម្រើនធម៌ភាវនាព្រឹកល្ងាច ត្រូវតែរស់នៅកន្លែងស្ងប់ស្ងាត់ហាត់កាយចិត្តតាមគន្លងធម៌អាថ៌ ទីនេះសម្រាប់តែគ្រហស្ថមិនទាន់អស់គ្រឿងសៅហ្មង, បើឱ្យយាយនៅទីនេះដែរ បានសេចក្តីថាបង្ខំយាយឱ្យឃ្លាតឆ្ងាយពីធម៌អាថ៌ នាំដល់ការបាត់បង់កុសល ដែលខំបួសភាវនារាប់សិបឆ្នាំ ។ សូមទូលថ្វាយតាមត្រង់ថា យាយពេញចិត្តរាជធីតាណាស់, ទាស់តែសំនួមពរឃ្លាតពីជីវភាពបព្វជិត ទើបយាយពុំអាចទទួលយកបាន, សូមរាជធីតាអភ័យទោស ។

ថ្មីបើពួនិយាយដូច្នេះ តែរាជធីតានៅតែទទូច :

- អ្នកម៉ែមិនទាន់យល់ទេ, វិមាននេះមានបន្ទប់ទំនេរច្រើនណាស់ បន្ទប់ខ្លះអាចរៀបចំបានស្ងប់ស្ងាត់ដូចអាស្រមអ្នកម៉ែដែរ ។ កូនធានារៀបចំជូននូវភាពសមស្របគ្រប់បែបយ៉ាង ដើម្បីកុំឱ្យអ្នកម៉ែឃ្លាតឆ្ងាយធម៌អាថ៌, សូមអ្នកម៉ែអញ្ជើញទៅពិនិត្យបន្ទប់ ហើយជ្រើសរើសតាមសព្វហឫទ័យ ។ ទោះយ៉ាងណាក៏កូននៅតែអង្វរអ្នកម៉ែដដែល, សូមអ្នកម៉ែជាទីសក្ការៈកុំទៅណាចោលកូន, សូមនៅក្បែរកូនជារៀងរហូត ។

គោលដៅរបស់ជនឃោរឃៅ គឺជ្រៀតចូលវិមានអាឡាដាំងឱ្យបាន ទោះដោយវិធីណាក៏ដោយ ។ រស់នៅក្នុងវិមានក្រោមការឧបត្ថម្ភរបស់រាជធីតា វាអាចធ្វើសកម្មភាពបានសព្វយ៉ាង ងាយជាងរស់នៅអាស្រម ហើយត្រូវត្រឡប់ទៅត្រឡប់មករាល់ថ្ងៃរវាងអាស្រមនិងវិមាន ។ ផែនការនេះវាព្រាងទុក តាំងពីពេលទើបក្រឡេកឃើញដូនជីហ្វាទីម ដូច្នេះហើយទើបវាសម្លាប់ដូនជីចោលបន្ទាប់ពីបានក្លែងមុខមាត់ដូចគាត់ ។ ឃើញរាជធីតាកាន់តែទទូចខ្លាំងឡើង វាធ្វើជាអង្គុយថ្លឹងពិចារណាមើលសិន អត់ទាន់ថាព្រមឬមិនព្រមទេ, អង្គុយស្ងៀមមួយសន្ទុះទើបវានិយាយ :

- រាជធីតា, ថ្មីបើបានកំណត់ខ្លួនឯងរាប់សិបឆ្នាំមកហើយថាត្រូវតែរស់នៅឆ្ងាយគ្រឿងកិលេសសៅហ្មង តែពេលនេះពុំដឹងហេតុ



យ៉ាងណាបែរជាទន់ចិត្តស្លុកចំពោះការអង្វររបស់បរិស័ទម្នាក់ដូចរាជធីតា ។ សូមទូលថ្វាយតាមត្រង់ថារាជធីតាជាមនុស្សទីមួយ ដែលអាចអូសទាញយាយឱ្យចេញមករស់នៅក្រៅអាស្រម, រាជធីតាជាមនុស្សទីមួយដែលយាយហាក់ដូចមិនដាច់ចិត្តទុកឱ្យស្រពាប់ស្រពោន ។

ប៉ុន្មានម៉ាត់របស់ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកធ្វើឱ្យរាជធីតាត្រេកអររកអ្វីប្រៀបពុំបាន ព្រះនាងស្ទុះក្រោកភ្លែត :

- បើអ៊ីចឹងសូមអ្នកម៉ែអញ្ជើញជាមួយកូនទៅមើលបន្ទប់, មានធំមានតូច មានគ្រប់របៀបស្ថាបនា, អ្នកម៉ែពេញចិត្តមួយណាក៏បាន ហើយបើចង់រៀបចំថែមយ៉ាងម៉េចឱ្យសមស្រប សូមប្រាប់កូនមកចុះ ។

ជនឃោរឃៅក្បាដំណើរស្រគត់ស្រគុំក្រោកដើរតាមរាជធីតា ។ បន្ទាប់ពីឆ្លងកាត់បន្ទប់ជាច្រើន ដែលមួយណាក៏ស្អាតភ្លឹង និងប្រកបដោយក្បូរក្បាច់ប្រណីតឆើតឆាយ ទីបំផុតវាជ្រើសបន្ទប់មួយអន់ជាងគេ ហើយធ្វើជានិយាយថា សម្រាប់វាដែលជាអ្នកលះបង់លោភៈបន្ទប់នោះល្អហួសពេកផង, តាមថាមិនសក្តិសមដល់ការស្នាក់នៅរបស់អ្នកបួសទេ តែដោយចង់ឱ្យរាជធីតាសប្បាយព្រះទ័យ ទើបវាយល់ព្រមនៅមួយគ្រាចុះ ។ វាបញ្ជាក់ទៀតថា បន្ទប់ហ្នឹងអាចផ្តល់ភាពស្ងប់ស្ងាត់បាន សមស្របគ្រាន់បើហើយ មិនបាច់រៀបចំថែមថយនាំតែខាតពេលទេ ។

រាជធីតាថ្លែងអំណរគុណជនកំណាចដែលរហូតមកទល់ពេលនេះ

ព្រះនាងនៅតែជឿស្លុងថាជាដូនជីហ្វាទីម រួចអញ្ជើញវាត្រឡប់ទៅបន្ទប់ទទួលភ្ញៀវមានបង្អួចម្ដេប្លូន ដើម្បីទទួលទានបាយទឹកជាមួយព្រះនាងមួយពេល ។ ប៉ុន្តែវាខ្លាចបែកការណ៍ ព្រោះពេលបាយទឹកត្រូវតែទម្លាក់កន្លែងទទូរក្បាលឱ្យសមរម្យជាភ្ញៀវក្នុងពិធីជប់លៀង មិនអាចគ្រលុំនាពេលនោះបានឡើយ ។ គិតឃើញដូច្នេះវាប្រកែកញ៉ាញយកលេសអៀនមាត់. វាថាដោយហេតុធ្លាប់តែទទួលទានបាយម្នាក់ឯងរាប់សិបឆ្នាំ ឥឡូវទទួលទានមានគ្នាដូច្នេះ អៀនមាត់លេបមិនចូល ។ម្យ៉ាងទៀតចំណីចំណុកដ៏ពេញពាស ក៏វាមិនអាចទទួលទានបានដែរ ព្រោះរាប់សិបឆ្នាំមកហើយ វាទទួលទានតែនំប៉័ងនិងបន្លែបន្តិចបន្តួច. សូមអនុញ្ញាតឱ្យបាននៅទទួលទានក្នុងបន្ទប់ម្នាក់ឯងជាមួយនំប៉័ងធម្មតាផ្ទាប់បន្លែស្រស់ ។

ជនឃោរឃៅអង្វរហើយអង្វរទៀត សូមកុំបង្ខំវាអនុវត្តផ្ទុយពីទម្លាប់ដ៏យូរលង់នេះ ។ ទីបំផុតរាជធីតាក៏យល់ប្រមតាមសំនូមពរវា ព្រះនាងលើកព្រហស្តប្រណម្យតប :

- បើទម្លាប់នេះពុំអាចកែប្រែបានអ៊ីចឹង កូនលែងហ៊ានបង្ខំអ្នកម៉ែហើយ ។ មិនអីទេ. ចាំកូនឱ្យគេយកចំណីមកជូន ។ ប៉ុន្តែសូមអ្នកម៉ែសន្យាថា ក្រោយពេលពិសារួច អ្នកម៉ែនឹងអញ្ជើញឡើងសាលទទួលភ្ញៀវសំណេះសំណាលលេងជាមួយកូន ។ សូមអ្នកម៉ែជឿថាកូនចង់នៅក្បែរអ្នកម៉ែជានិច្ច ។



- បើគ្រាន់តែសំនូមពរប៉ុណ្ណឹងយាយអាចទទួលបានដោយរីករាយ. (ជនកំណាចឆ្លើយតបព្រមទាំងនិយាយបន្ត) រាជធីតាជាបរិស័ទម្នាក់ដែលមិនត្រឹមតែអាចធ្វើឱ្យយាយទន់ចិត្តប៉ុណ្ណោះ ថែមទាំងជាបរិស័ទម្នាក់ដែលយាយហាក់ដូចមាននិស្ស័យចង់តែសំណេះសំណាលដោយឥតធុញទ្រាន់ ។

រាជធីតាគោរពជនឃោរឃៅម្ដងទៀត រួចយាងចេញពីបន្ទប់ ។ ក្រោយនោះមិនយូរប៉ុន្មាន ពេលបញ្ចប់ការសោយក្រយានៅសាលទទួលភ្ញៀវ ព្រះនាងគិតថាដូនជីជាទីសក្ការៈរបស់ព្រះនាង ប្រហែលបញ្ចប់ការទទួលទានតាមបែបទុក្ករកិរិយាដែរ ក៏ប្រើភីលៀងម្នាក់ឱ្យទៅអញ្ជើញ ។ លុះជនកំណាចឡើងមកដល់ ព្រះនាងនាំវាអង្គុយលើកៅអីខ្ពស់ ហើយចាប់ផ្ដើមសំណេះសំណាលលេងជុំវិញសកម្មភាពសាងអំពើល្អ ដែលដូនជីហ្វាទីមបានអនុវត្តកន្លងមក. និយាយរឿងនោះមួយសន្ទុះ ព្រះនាងទាញចូលរឿងវិមានអាឡាដាំងម្ដង ដោយលើកព្រះហស្តប្រណម្យស្មើ :

- អ្នកម៉ែ ! កូនរីករាយណាស់ដែលបានអ្នកម៉ែនៅជាមួយដើម្បីប្រទានពរកូន និងវិមានលំនៅរបស់កូននេះ ។ កូនចេះតែមានអារម្មណ៍ថា អ្នកម៉ែថ្វីបើបួសភាវនាធមិអាចិរក្សាស្ងប់ស្ងាត់តាំងពីក្មេង តែអ្នកម៉ែពិតជាមានភ្នែកទិព្វអាចមើលយល់ចំណុចខ្វះខាត ឬគ្រប់គ្រាន់របស់ស្ថាបត្យកម្មនីមួយៗ ហើយអាចផ្ដល់យោបល់បានល្អៗ ។

កូនចង់នាំអ្នកម៉ែដើរមើលវិមានមួយត្រួស ដើម្បីជួយបង្ហាញនូវការខ្វះខាតដល់កូន ។ ប៉ុន្តែមុននឹងអញ្ជើញមើលកន្លែងផ្សេងៗ ដំបូងបង្អស់សូមអ្នកម៉ែជួយឱ្យយោបល់ចំពោះរាលទទួលភ្ញៀវនេះសិន. តើអ្នកម៉ែឃើញយ៉ាងណាដែរ?

ដូនជីហ្វាទីមក្លែងក្លាយពិតជាប្រសប់ដើរតួសង្រួមបោកប្រាស់. តាំងពីចូលមកដល់ដឹងតែសម្លឹងត្រង់ទៅមុខក្នុងចម្ងាយមិនលើសបីព្យាម. សូម្បីងាកឆ្វេងស្តាំក៏មិនដែលងាកផង. ឥឡូវឮស្នើដូច្នេះវាធ្វើជាងើយមើលជុំវិញខ្លួនមួយត្រួស រួចមើលឡើងដំបូលក្រឡូមខ្ពស់ ។ បន្ទាប់ពីបង្ហាញឱ្យឃើញថា ខ្លួនមានការចាប់អារម្មណ៍ផ្នែកខាងក្រោមដំបូល. វាជ្រួញចិញ្ចើមបន្តិច ហើយបន្លឺយឺតៗ :

- ក្រាបទូលរាជធីតា. សាលទទួលភ្ញៀវនេះស្អាតអស្ចារ្យពន់ពេកណាស់ ពុំអាចរកសាលទទួលភ្ញៀវណាផ្សេងមកប្រៀបផ្ទឹមបានទេ។ ប៉ុន្តែតាមយោបល់យាយដែលជាអ្នកធ្លាប់រស់ត្រមង់ត្រមោច យាយឃើញនៅខ្វះចំណុចមួយ. ប្រសិនបើពុំខ្វះចំណុចនោះ ម្ល៉េះសាលពេញលេញសោភណភាពគួរឱ្យគាប់ភ្នែកបំផុត ។ យាយសូមបញ្ជាក់ថានេះជាយោបល់ដោយឡែករបស់យាយទេ ។ យាយមិនមែនស្ថាបត្យករដូច្នេះយាយក៏មិនហ៊ានអះអាងថាយោបល់របស់ខ្លួនត្រឹមត្រូវ ឬខុសដែរ ។

- សាធុអ្នកម៉ែ ! (រាជធីតាកញ្ច្រៀវដោយអំណរ) កូនយល់



មិនខុសមែន. អ្នកម៉ែពិតជាចេះមើលយ៉ាងចំណាប់ និងផ្តល់ដំបូន្មានបានល្អបំផុត ។ តើសាលទទួលភ្ញៀវនេះនៅខ្វះអីទៀតទើបបញ្ចេញសោភណភាព. អ្នកម៉ែ?

- សូមរាជធីតាអភ័យទោសយាយ ចំពោះការហ៊ានលើកឡើងតាមទស្សនៈរបស់ខ្លួនដ៏ប្រថុយប្រថាន ។ របស់ដែលយាយមើលឃើញថាខ្វះនោះគឺស៊ុតឥន្ទ្រីណា ។

- ស៊ុតឥន្ទ្រី? (រាជធីតាឧទានដោយភ្ញាក់) យកស៊ុតឥន្ទ្រីមកធ្វើម៉េច. អ្នកម៉ែ !

ជនកំណាចចង្អុលដំបូលក្រឡូមខ្ពស់ :

- បើរកបានស៊ុតឥន្ទ្រីមួយព្យួរចំពីក្រោមដំបូល វានឹងជួយគួបផ្សំសោភណភាពធ្វើឱ្យសាលទទួលភ្ញៀវរបស់រាជធីតាកាន់តែមានភាពប្រណិតឆើតឆាយ និងលេចចេញនូវលក្ខណៈអស្ចារ្យដាច់គេមួយផែនដី។ តាមថាចំណុះនេះសាមញ្ញសោះ ទាស់តែស្ថាបត្យករយល់មិនដល់ ឬធ្វេសប្រហែសទើបប៉ុន្មានឆ្នាំហើយ សាលទទួលភ្ញៀវដ៏គួរជាទីមោទនភាពបំផុតមិនអាចរំលេចសោភណភាពបានមួយរយភាគរយ ។ បើរាជធីតាជឿសំដីយាយ. តោងខិតខំប្រាប់ប្តីឱ្យគាត់ដោះស្រាយទៅយកស៊ុតឥន្ទ្រីតុបតែងថែម ។

រាជធីតាសួរដេញដោល :

- ឥន្ទ្រីជាសត្វប្រភេទយ៉ាងម៉េចអ្នកម៉ែ? នៅឯណាទើបមាន.

ហើយដើម្បីយកស៊ុតវាបានតើត្រូវធ្វើម៉េច? សូមអ្នកម៉ែជួយប្រាប់លម្អិតបន្តិចទើបកូនយល់ ។ កូនធានាខិតខំអស់លទ្ធភាពដោះស្រាយឱ្យយោបល់របស់អ្នកម៉ែក្លាយជាការពិតក្នុងពេលឆាប់ៗ មិនបណ្ដោយឱ្យអ្នកម៉ែខកចិត្តទេ ។

ជនកំណាចបង្ហាញការយកចិត្តទុកដាក់, និយាយពន្យល់ :

- ក្រាបទូលរាជធីតា, ឥន្ទ្រីគឺជាមហាបក្សីមួយធំបំផុតក្នុងលោក សូម្បីរកពីព្រៃ រមាស ដំរីក៏ជាចំណីរបស់វាដែរ ។ វារស់នៅលើកំពូលខ្ពស់ជាងគេនៃជួរភ្នំកូកាស៍ ។ អ្នកស្ថាបនាវិមាននេះគឺជាអ្នកអាចទៅយកស៊ុតឥន្ទ្រីថ្វាយព្រះនាងបាន, ក្រៅពីនោះពុំដែលឮថាមានអ្នកណាទៅដល់ ព្រោះតាមផ្លូវពោរពេញដោយគ្រោះថ្នាក់សត្វសាហាវ តែបើទុកជាទៅដល់ក៏ពុំអាចយកមកបាន ។

រាជធីតាថ្លែងអំណរគុណដូនជីហ្វាទីមក្លែងក្លាយដែលបានផ្ដល់យោបល់ល្អប្រសើរ, រួចហើយបន្តការសំណេះសំណាលទៀត តែទោះសំណេះសំណាលរឿងអីក៏អារម្មណ៍ព្រះនាងចេះតែវិលវល់ជុំវិញបញ្ហាស៊ុតឥន្ទ្រី,។ មិនតែប៉ុណ្ណោះព្រះនាងសម្រេចព្រះទ័យថា នឹងពិគ្រោះជាមួយអាឡាដាំង ពេលនាយត្រឡប់មកពីបរបាញ់ ។

គួរបញ្ជាក់ដែរថា អាឡាដាំងទៅបរបាញ់កំសាន្តតាំងពីប្រាំមួយថ្ងៃមុនម្ល៉េះ ។ ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកដោយដឹងច្បាស់ពីអវត្តមាននេះ ទើបហ៊ានបន្លំធ្វើដូនជីហ្វាទីមបោកប្រាស់រាជធីតា ដើម្បីបន្តិច



ទៀតសម្រេចផែនការសងសឹករបស់វា ។ វាចាប់ផ្ដើមទទួលជោគជ័យទីមួយល្មមពេលអាឡាដាំងត្រឡប់មកវិញ គឺនាយប់ថ្ងៃទីប្រាំមួយនោះតែម្ដង ។ នាយមកដល់ក្រោយពេលដូនជីហ្វាទីមក្លែងក្លាយ ទើបតែលារាជធីតាត្រឡប់ទៅបន្ទប់វា ដូច្នេះហើយទើបអត់ទាន់បានដឹងរឿងនេះ, នាយគិតតែប្រញាប់ប្រញាល់ទៅខាងបន្ទប់រាជធីតាឱបថើប និងសួរសុខទុក្ខប្រពន្ធចំពេលរាជធីតាកំពុងចុះពីសាលទទួលភ្ញៀវ ។

អាឡាដាំងចាប់អារម្មណ៍ឃើញរាជធីតា ថ្វីបើស្និទ្ធស្នាលជាមួយប្ដីដូចធម្មតា តែក្នុងនោះហាក់ដូចមានអ្វីស្រពាប់ស្រពោនបន្តិច។ អាការៈនេះធ្វើឱ្យនាយនឹកឆ្ងល់សួរត្រង់ៗ :

- បងសម្គាល់ឃើញរាជធីតាមានការខ្វល់ខ្វាយអ្វីម្យ៉ាង, ឬក៏ក្នុងរយៈពេលបងទៅបរបាញ់នោះមានឧប្បត្តិហេតុអាក្រក់កើតឡើង? សូមរាជធីតាកុំលាក់, បងធានាប្រឹងប្រែងអស់លទ្ធភាពដោះស្រាយធ្វើឱ្យរាជធីតាលែងស្រពាប់ស្រពោនក្នុងហឫទ័យ ។

ដំបូងរាជធីតាគិតថាមិនទាន់ប្រាប់ប្ដីភ្លាមៗទេ ចាំពេលបាយទឹកជួបជុំគ្នាសឹមនិយាយ ឥឡូវឮសួរចំដូច្នេះលាក់ទៅទៀតលែងកើតព្រះនាងក៏ញញឹមតប :

- អូនរស់ក្នុងសុភមង្គលល្អណាស់ ពុំមានឧប្បត្តិហេតុអ្វីធ្វើឱ្យល្អក់កករសូម្បីបន្តិចបន្តួចទេ គ្រាន់តែមានរឿងមួយប៉ុណ្ណោះធ្វើឱ្យអូនដក់អារម្មណ៍, មិននឹកស្មានថាការខ្វាយខ្វល់នោះដិតលើផ្ទៃភក្ត្រធ្វើឱ្យ

បងសម្គាល់ឃើញបាន ។ ដូច្នេះបំណាច់បងដឹងទៅហើយ អូនក៏មិនលាក់ទៀតដែរ ថ្វីបើរឿងនោះតូចតាច ។ ប្ដីសម្លាញ់, តាំងពីដើមមកអូនក៏ដូចបង ពេលណាក៏នឹកស្មានថាវិមានរបស់យើងតុបតែងប្រកបដោយសោភណភាពដាច់គេលើផែនដី កន្លែងណាក៏សុក្រិតឥតខ្ចោះ ប៉ុន្តែពេលនេះអូនសូមជម្រាបបងពីគំនិតមួយ ដែលទើបមកដល់សម្រាប់អូន ។ ពុំដឹងបងយល់អ៊ិចឹងដែរទេ តែចំពោះអូនវិញ អូនឃើញថា សាលទទួលភ្ញៀវមានបង្អួចម្ដេកប្អូននោះនៅខ្វះចន្លោះបន្តិច បើបានវត្ថុ មួយទៀតដាក់តាំងចំពីក្រោមដំបូលក្រឡូមខ្ពស់ វានឹងក្លាយជាសាលប្រកបដោយសោភណភាពសុក្រិតបំផុត ។ អូនចេះតែមានអារម្មណ៍ ចង់ឱ្យវិមានរបស់យើងកាន់តែត្រូវបានអ្នកផងឃើញប្រណីតឆើតឆាយ, សក្តិសមគ្រប់ផ្នែក មិនចង់ឮអ្នកណាម្នាក់និយាយថា នៅអន់កន្លែងនេះ ឬស្ទើរកន្លែងនោះទេ ។

អាឡាដាំងមិននឹកស្មានខ្លួនឮពាក្យទាំងនេះពីប្រពន្ធជុំវិញបញ្ហាវិមាន ព្រោះខ្លួនធ្លាប់តែមានមោទីភាពថា សាលទទួលភ្ញៀវសុក្រិតក្នុងបែបផែនសោភណភាពម្យ៉ាងពេញលេញបំផុត គ្មានស្ថាបត្យកម្មណាមួយលើផែនដីអាចប្រៀបផ្ទឹមបាន ។ នាយសួរដោយងឿងឆ្ងល់:

- របស់នោះជាអ្វីទៅ?

រាជធីតាបាទ្រូប៊ូឌូដែលជឿសម្ដីពិសពុលរបស់ជនកំណាចមួយរយភាគរយ ឆ្លើយដោយគ្មានរារែក :



- គឺស៊ុតមហាបក្សីឥន្ទ្រី. យកស៊ុតនោះមកព្យួរចំពីក្រោមដំបូល ។

អាឡាដាំងអង្គុយស្ងៀមនឹកឡើងវិញពីរូបរាងសាលទទួលភ្ញៀវ តាំងពីកម្ពស់រហូតដល់ទំហំនិងបែបផែនតុបតែងផ្សេងៗ. គិតមួយសន្ទុះនាយងក់ក្បាល :

- ប្រហែលអីចឹងមែន. នៅចំពីក្រោមដំបូលក្រឡូមនោះមានចោលចន្លោះធំពេក អាចបណ្ដាលឱ្យឃើញល្វឹងល្វើយដូចការកត់សម្គាល់របស់រាជធីតា ។ ដូច្នេះ បើបានស៊ុតឥន្ទ្រីមួយព្យួរលម្អថែមប្រហែលសមភ្នែកជាងមុន ។ មិនអីទេ. ដើម្បីឱ្យរាជធីតាសប្បាយហឫទ័យបងសន្យារកស៊ុតឥន្ទ្រីឱ្យទាល់តែបាន. ពេលយកបានហើយ បងប្រគល់ឱ្យរាជធីតាតុបតែងផ្ទាល់តាមលក្ខណៈសោភណភាពណាក៏ដោយ ដែលរាជធីតាចង់បាន ។

បន្ទាប់នោះ នាយលាប្រពន្ធ ឡើងទៅសាលទទួលភ្ញៀវមានបង្អួចម្ដេកប្អូន. យកចង្កៀងទិព្វចេញពីខ្លួន ។ តាំងពីថ្ងៃរងគ្រោះម្ដងក្រោមស្នាដៃគ្រូធ្មប់អាហ្វ្រិក ចង្កៀងទិព្វនោះនាយដាក់ជាប់តាមខ្លួនរហូត. សូម្បីគ្រាន់តែចូលរាំងគាល់បិតាក្មេកក៏យកតាមដែរ ។ នាយដុសម្រាមដៃហៅទេពចម្លែក. រួចចេញបញ្ជា :

- អ្នកឯងមើលនែ. ក្រោមដំបូលក្រឡូមខ្ពស់ខ្វះស៊ុតឥន្ទ្រីមួយព្យួរលម្អ ។ ក្នុងនាមចង្កៀងទិព្វដែលយើងកំពុងកាន់នេះ យើងពឹងអ្នកឯងឱ្យទៅយកស៊ុតឥន្ទ្រីមួយមក ទោះដោយវិធីណាក៏ដោយ ដើម្បី

បំពេញការខ្វះចន្លោះ ។ យើងជឿថាកិច្ចការត្រឹមប៉ុណ្ណឹងអ្នកឯងពិតជាអាចធ្វើបានដោយគ្មានពិបាក ហើយក៏មិនបាច់ចំណាយពេលច្រើនដែរ។ យើងចង់ឃើញអ្វីៗចប់រួចរាល់ក្នុងពេលបន្តិចទៀត ។

ប៉ុន្តែលើកនេះខុសស្រឡះមុនៗ. នាយនិយាយចប់សឹងមិនទាន់ស្រាប់តែទេពចម្លែកសន្ទាប់លាន់ខ្ទរជាមួយអាការៈក្រេវក្រោធ ធ្វើឱ្យនាយភ្ញាក់ស្ទុះទ្រេតទ្រោតមកក្រោយ វិះបន្តិចទៀតផ្ងារទាំងជំហរលើកម្រាល ។ ទឹកមុខកាចរបស់ទេពចម្លែកនាំដល់ការតក់ស្លុតផងឆ្ងល់ផង នាយស្រែកសួរវិញ :

- ម៉េចអ៊ីចឹង? ម៉េចមានអាកប្បកិរិយាបែបនេះជាមួយយើង? ឬក៏អ្នកឯងតាំងខ្លួនខ្លាំងពូកែលែងជាទាសកររបស់ចង្កៀងទិព្វក្នុងដៃយើងនេះទៀត ?

ទេពចម្លែកគ្រហឹមយ៉ាងកាច. សម្លេងគ្រហឹមនោះ ទោះអ្នករឹងប៉ឹងយ៉ាងណាក៏តក់ស្លុតដែរ ។ គាត់បង្ហាញភាពខឹងសម្បារកាន់តែច្បាស់ឡើង ស្រែកដាក់អាឡាដាំងវិញ :

- ហ៊ឹះ. មនុស្សអត់ដឹងខ្យល់ ! មនុស្សស៊ីបាយបោកឆ្នាំង ! មិត្តទាំងឡាយរបស់យើងនិងរូបយើងបានពួតដៃគ្នាយ៉ាងស្ម័គ្រស្មោះធ្វើឱ្យអ្នកឯងឈានឡើងឥតឈប់ឈរ រហូតដល់ក្លាយជាមហាបុរសលេខមួយលើផែនដី សូម្បីស្តេចចក្រពត្តិក៏ពុំអាចប្រៀបផ្ទឹមបាន ។ ប៉ុណ្ណឹងហើយអ្នកឯងមិនទាន់សប្បាយចិត្តទៀតឬអី បានជាពេលនេះ



ចេញកាឡាសារមិលគុណដល់កម្រិតកំពូលចង់យកចៅហ្វាយធំរបស់យើងមកព្យួរកក្រោមដំបូលសាលទទួលភ្ញៀវរបស់អ្នកឯង ។ នែ. ការប្រមាថមើលងាយចៅហ្វាយនាយដ៏ខ្ពង់ខ្ពស់របស់យើងនេះ ត្រូវតែទទួលការផ្តន្ទាទោសធ្ងន់ធ្ងរបំផុត យ៉ាងហោចណាស់ក៏ត្រូវបំផ្លាញចោលទាំងអស់នូវអ្វីដែលធ្វើឱ្យអ្នកឯងបានរុងរឿងកន្លងមក ពិសេសវិមាននេះនឹងរលាយជាផេះផង់ក្នុងមួយពព្រិចភ្នែក. ហើយជីវិតអ្នកឯងក៏ពុំអាចគង់វង្សដែរ ។ ប៉ុន្តែ. ចាត់ថាជាសំណាងរបស់អ្នកឯងនៅមាននៅឡើយដែលអ្វីៗមិនមែនអ្នកឯងបង្កឡើង។ ការចង់បាននេះមិនមែនអ្នកឯងគិតឃើញដោយខ្លួនឯង កុំអីត្រូវរលាយទាន់ហន់ ពេលអ្នកឯងនិយាយចប់ភ្លាម ។ ដឹងទេ. មេខ្យល់បង្កើតឱ្យមានការប្រមាថមាក់ងាយចៅហ្វាយធំដ៏ខ្ពង់ខ្ពស់របស់យើងនោះជានរណា? ប្រភេទមនុស្សយ៉ាងម៉េច? ផែនការរបស់គេមានទិសដៅយ៉ាងម៉េច? ដឹងឬមិនដឹង?

អាឡាដាំងឡឹងឡង់អត់យល់អ្វីសោះ. បន្ទឹសួរវិញ :

- យើងសូមសារភាពត្រង់ថា យើងអត់បានដឹងអ្វីដូចដែលសំនួរបានលើកឡើងទេ. តើគេនោះជានរណាដែរ? ប្រពន្ធយើងឬ?

ទេពចម្លែកបញ្ចេញស្នូរហ៊ឹះម្តងទៀតទើបឆ្លើយ :

- យើងប្រាប់ឱ្យភ្លឺភ្នែកទៅចុះ. មិនមែនរាជធីតាទេ ។ រាជធីតាជាមនុស្សល្អបំផុត ទាស់តែឆាប់ជឿគេពេកទើបមានរឿងនេះ

កើតឡើង ។ តាមពិតគេនោះគឺប្អូនប្រុសបង្កើតរបស់គ្រូធ្មប់អាហ្វ្រិកសត្រូវលេខមួយរបស់អ្នកឯង ។ វាកំពុងឋិតនៅយ៉ាងសុខស្រួលក្នុងវិមានអ្នកឯង ដោយសារក្លែងខ្លួនធ្វើជាដូនជីហ្វាទីមបន្លំភ្នែករាជធីតាបាន ។ ចំណែកដូនជីហ្វាទីមពិតប្រាកដត្រូវវាសម្លាប់ហើយ ។ វាជាអ្នកផ្ដល់គំនិត ប្រាប់រាជធីតាពីការខ្វះសោភណភាពក្នុងសាលទទួលភ្ញៀវ ដើម្បីឱ្យរាជធីតារំអុកអ្នកឯងឱ្យប្រព្រឹត្តអំពើរមិលគុណយ៉ាងធ្ងន់ធ្ងរបំផុត ដូចដែលខ្លួននិយាយអម្បាញ់មិញ ។

អាឡាដាំងបែកញើសស្រាក់ៗ នៅពេលការពិតប៉ុនជីវិតទាំងមូលត្រូវបានទេពចម្លែកបំភ្លឺ, វិះបន្តិចទៀតរលាយជាផេះផង់គ្មានសល់អ្វី ។ នាយនិយាយទាំងដង្ហក់ :

- សូមអរគុណចំពោះការពន្យល់ប្រាប់ដោយសុទ្ធចិត្ត ។ យើងពិតជាអត់បានដឹងអីមែន ទើបតែត្រឡប់ពីបរបាញ់ ទទួលឃើញរាជធីតាស្រពាប់ស្រពោននិយាយប្រាប់ក៏ជឿស្លុង ។

ទេពចម្លែកសម្រួលទឹកមុខវិញបន្តិច បន្ទាប់ពីសម្ដែងការក្រេវក្រោធសឹងផ្ទុះភ្លើងតាមក្បាល :

- ត្រូវប្រញាប់កម្ចាត់ជនឃោរឃៅនោះឱ្យបានមុន, ប្រយ័ត្នស្លាប់ខ្លួនដោយសារវា ។ ថាតែប៉ុណ្ណេះគាត់បំបាំងខ្លួនទៅបាត់ ។

អាឡាដាំងបញ្ចេញដង្ហើមវែងលាន់ឮ ! ធូរទ្រូងខ្យាក ។ សម្ដីទេពចម្លែកលាន់ខ្ទរពេញត្រចៀកនាយនៅឡើយ ។ នាយធ្លាប់ល្បីកេរ្តិ៍



ឈ្មោះដ៏ក្រអូបរបស់ដូនជីហ្វាទីមតាំងពីយូរ, ពិសេសដឹងពីទុក្ករកិរិយានិងការដើរចច្រប់ប្រទានពររបស់គាត់ និងលទ្ធភាពដែលអាចអង្អែលក្បាលកម្ចាត់រោគាមិនឱ្យបៀតបៀនបាន ។ អ្នកបួសដូចគាត់គួរជាទីសក្ការៈបូជាបំផុត ។ ឥឡូវជនកំណាចចិត្តពាលហ៊ានសម្លាប់គាត់ ដើម្បីបន្លំខ្លួនចូលវិមានរបស់នាយ ។ គោលដៅរបស់វាប្រាកដណាស់ គឺទីមួយសងសឹកឱ្យបងវា ទីពីរដណ្ដើមយកចង្កៀងទិព្វដើម្បីរាតត្បាតពិភពលោក ។

នាយសង្កៀតធ្មេញនឹកក្នុងចិត្ត : "ទាំងបងទាំងប្អូនវាសុទ្ធសឹងសត្រូវរបស់មនុស្សជាតិ, យើងត្រូវតែកម្ទេចឱ្យផុតពូជ ដើម្បីសងសឹកជូនដូនជីហ្វាទីម ក៏ដូចជាបណ្ដាអ្នកធ្លាប់រងគ្រោះដោយសារអំពើធ្មប់អាបរបស់ពួកវា" ។

មិនបង្អង់យូរ អាឡាដាំងយកចង្កៀងទិព្វទុកក្នុងខ្លួន ហើយចុះទៅបន្ទប់រាជធីតាវិញ ។ នាយអត់និយាយអ្វីពាក់ព័ន្ធដល់ការងារយកស៊ុតមហាឥន្ទ្រីទេ, ចុះដល់ធ្វើជាដកដង្ហើមញាប់របៀបហេវហត់ ទម្លាក់ខ្លួនអង្គុយលើកៅអី ដៃច្របាច់ថ្ងាសទាំងមុខជូរ ។ រាជធីតាឃើញប្ដីកំពុងសុខៗស្រាប់តែប្រែប្រួលចម្លែកពេក ព្រះនាងភិតភ័យស្ទុះចូលឱបរឹតបន្ទីសួរ :

- បង ! បងយ៉ាងម៉េចហ្នឹង? មិនស្រួលខ្លួនមែនទេ ?

អាឡាដាំងកាន់តែច្របាច់ថ្ងាសខ្លាំងឡើង ច្របាច់ផងនិយាយផង :

- បងឈឺក្បាលណាស់. អម្បាញ់មិញឈឺតិចល្មមអាចទ្រាំបាន តែឥឡូវខ្លាំងមែនទែន អង្គុយលែងចង់កើតទៅហើយ ។ ពីដើមមក បងមិនដែលអ៊ីចឹងសោះ. នេះប្រហែលមកពីទៅបរបាញ់ហាលក្ដៅហាលខ្យល់ច្រើនពេកក៏មិនដឹង ។ រាជធីតាមានវិធីអាចជួយបងភ្លាមៗបានទេ?

ឮដូច្នេះ រាជធីតាអះអាងភ្លាម :

- ប្ដីសម្លាញ់កុំភ័យ. បងនឹងបានជាក្នុងពេលបន្តិចទៀតនេះ អម្បាញ់មិញដោយប្រថុចញ៉ុចពេកអូនមិនទាន់បានជម្រាបបងពីរឿងដូនជីហ្វាទីមជាទីសក្ការៈនៅឡើយ ។ ព្រឹកមិញអូនបានអង្វរអញ្ជើញដូនជីហ្វាទីមមកនៅជាមួយយើង. ឥឡូវគាត់កំពុងសម្រាកក្នុងបន្ទប់ស្ងាត់មួយ ។ បន្តិចទៀតគាត់អញ្ជើញមកដល់ បងពិតជាបាត់ឈឺក្បាល

វិលមុខដោយសារបាតដៃសម្រេចមគ្គផលដ៏សក្ដិសិទ្ធិរបស់គាត់ ។

ថាហើយព្រះនាងហៅភីលៀងម្នាក់ ប្រាប់ឱ្យទៅបន្ទប់ជនឃោរឃៅ ជម្រាបថាអាឡាដាំងត្រឡប់ពីបរបាញ់វិញ ស្រាប់តែឈឺក្បាលខ្មោចៗមកពីហាលក្ដៅហាលខ្យល់យូរពេក. សុំឱ្យវាមកជួយសង្គ្រោះតាមវិធីប្រទានពរជ័យដូចដែលធ្លាប់ធ្វើចំពោះបរិស័ទនានាកន្លងមក ។ ពេលនោះប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកកំពុងគិតផែនការសងសឹកនិងផែនការដណ្ដើមយកចង្កៀងទិព្វ ទទួលឃើញភីលៀងម្នាក់រត់មកប្រាប់ដូច្នេះនឹកអរភើតគិតថាអ្វីៗប្រព្រឹត្តទៅជាមួយអំណោយផល



ល្អហួសការស្មាន ។ វាម្នីម្នាលាក់កាំបិតស្នៀតក្នុងចង្កេះ ហើយរៀបដំណើរស្រគត់ស្រគុំដើរមកបន្ទប់រាជធីតា ។

អាឡាដាំងអង្គុយធ្វើមុខជូរដូចមនុស្សមិនស្រួលខ្លួនមែនទែន. តែត្រចៀកផ្ទៀងស្ដាប់ជុំវិញខ្លួន ក្រែងមានហេតុភេទចៃដន្យណាមួយកើតឡើង ។ នាយឃើញដូនជីហ្វាទីមក្លែងក្លាយដើរចូល ក៏លើកដៃប្រណម្យវន្ទាតាមរបៀបគោរពអ្នកបួស ហើយនិយាយក្នុងស្នូរដង្ហើមហេវហត់ :

- កូនធ្លាប់ឮកេរ្តិ៍ឈ្មោះក្រអូបសុះសាយរបស់អ្នកម៉ែយូរហើយ ទើបតែថ្ងៃនេះមានសំណាងបានជួបផ្ទាល់ ។ ហេតុតែកូនមាននិស្ស័យជាមួយអ្នកម៉ែ ទើបព្រះជាម្ចាស់នាំអ្នកម៉ែមករកកូនចំពេលកូនមានជំងឺ ។ ជាមួយជំនឿមុតមាំនិងចិត្តជ្រះថ្លាបំផុត កូនសូមអង្វរអ្នកម៉ែមេត្តាប្រទានពរបំបាត់រោគ ឈឺក្បាល វិលមុខរបស់កូន ដូចដែលអ្នកម៉ែតែងអនុវត្តសង្គ្រោះបរិស័ទតាំងឡាយក្នុងរាជធានីនេះ ។ នាយនិយាយក្នុងកាយវិការគោរពឱនលំទោនដូចកំពុងមានជំនឿស៊ុប តែតាមពិតភ្នែកច្បាមគ្រប់ចលនារបស់ជនកំណាច ដើម្បីត្រៀមបង្ក្រាបវាឱ្យបានទន់ពេលវេលា ។ ប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកអត់ដឹងខ្លួនសោះ គិតតែរីករាយនិងផែនការពិសពុលដែលវានឹងថាបានទទួលជោគជ័យលឿនហួសការស្មាន ។ ឃើញអាឡាដាំងឱនក្បាលមក វាក៏លូកដៃឆ្វេងប្រុងអង្អែលកំចាត់រោគ ដំណាលពេលដៃស្ដាំវាលូកចូលស្រទាប់

អាវដកកាំបិតស្នៀតពីចង្កេះ ។ អាឡាដាំងកាត់យល់ទាំងអស់ នាយវាសដៃឆ្វេងរិប ចាប់ដៃស្តាំវាជាប់អត់ឱ្យធ្វើចលនាបាន ឯដៃស្តាំស្រវាកាំបិតស្នៀតរបស់ខ្លួន ដែលត្រៀមមុនហើយស្រេច ចាក់លិចមួយកាំបិតចំបេះដូងវា រួចធាក់មួយជើងបណ្តាលឱ្យរាងកាយរបស់វារលំគ្រាំងប្រកាច់ដកចង្កាមាន់លើកម្រាល ។

រាជធីតាភ័យស្លន់ស្រែកភ្លាត់សម្លេង :

- យី. ម៉េចអ៊ីចឹង? គាត់ជាអ្នកបួសសង្គ្រោះសត្វលោក ពេលនេះកំពុងមកប្រទានពរសង្គ្រោះយើងទាំងអស់គ្នា ហេតុអីសម្លាប់គាត់?

អាឡាដាំងសើចស្ងួត :

- វាមិនមែនដូនជីហ្វាទីមទេ ។ វាជាប្អូនប្រុសបង្កើតរបស់គ្រូធ្មប់អាហ្វ្រិកដែលព្យាបាទយើងថ្ងៃមុននោះណា ។ ដូនជីហ្វាទីមត្រូវវាសម្លាប់ហើយ ។

ទន្ទឹមនឹងពាក្យប៉ុន្មានម៉ាត់នេះ នាយស្ទុះចូលកន្ត្រាក់កន្សែងពីក្បាលជនកំណាច បង្ហាញឱ្យឃើញសក់និងមួយចំហៀងក្បាលខាងក្រោយពិតជាមិនមែនដូនជីហ្វាទីម ។ បន្ទាប់នោះនាយលូកយកកាំបិតស្នៀតចេញពីចង្កេះវា លើកឡើងបង្ហាញទៀត ធ្វើឱ្យរាជធីតាកាន់តែបើកព្រះនេត្រធំៗ ។ បង្ហាញភស្តុតាង រួចនាយនិយាយ :

- ប្រសិនបើបងមិនបានដឹងមុន ម្ល៉េះត្រូវស្លាប់និងកាំបិតស្នៀតនេះពេលឱនក្បាលឱ្យវាស្ទាបអង្អែល ។ អានេះជាឧក្រិដ្ឋជនសាហាវ



ព្រៃផ្សៃរកលេខដាក់គ្មាន វាសម្លាប់ទាំងអ្នកបួសស្លូតត្រង់ ដើម្បីមហិច្ឆតាផ្ទាល់ខ្លួន ។ ទោសវានោះចិញ្ច្រាំមួយរយជាតិក៏មិនរួចដែរ ។

- រាជធីតាបាឌ្រូប៊ូឌូបន្ទាប់ពីយល់ការពិត ព្រះនាងសម្តែងការស្តាយក្រោយចំពោះប្តីសម្លាញ់. មេរៀនគួរឱ្យតក់ស្លុតជាមួយគ្រូធ្មប់អាហ្វ្រិកទើបតែកន្លងផុតប៉ុន្មានខែសោះ ស្រាប់តែឥឡូវព្រះនាងភ្លាត់ស្នៀតដោយសារប្អូនប្រុសគ្រូធ្មប់អាហ្វ្រិកទៀត ។ គ្រោះថ្នាក់ទាំងពីរលើកនេះ ប្រសិនបើអ្នកណាផ្សេងក្រៅពីអាឡាដាំង ពិតជាពុំអាចដោះស្រាយបានឡើយ ។

ប៉ុន្មានឆ្នាំក្រោយ ព្រះចៅក្រុងចិនទ្រង់សោយទីវង្គតបន្ទាប់ពីទ្រង់ប្រឈួនជាច្រើនខែ ។ ដោយហេតុព្រះអង្គគ្មានបុត្រា. រាជធីតាបាឌ្រូប៊ូឌូត្រូវបានឡើងស្នងរាជ្យបន្តវេនបិតា តែមិនយូរប៉ុន្មានព្រះនាងក៏ផ្ទេររាជសម្បត្តិឱ្យអាឡាដាំងវិញ ។ ដូច្នេះ. ពីតូនាទីតូចទាបបំផុតក្នុងសង្គម ធំឡើងស្រាប់តែអាឡាដាំងក្លាយជាស្តេចផែនដីបុរីក្រុងចិន សោយរាជ្យយ៉ាងសុខដុមជាមួយព្រះអគ្គមហេសីសំណប់ព្រះនាមបាឌ្រូប៊ូឌូ ។

**ចប់ភាគទី៤១ តែប៉ុណ្ណេះ**

**រឿងក្នុងភាគទី៤២ អស្ចារ្យណាស់ទៅទៀត**

**បើអស់លោកអ្នកណាខានមើល មុខជាស្តាយក្រោយ ។**